មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0113

សម្ភាសន៍ជាមួយឈ្មោះ ដោក សារ៉ាន ហៅ ដោក សារាំ ភេទប្រុស អាយុ៥១ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ កងចល័តឃុំផ្ដៅ

មុខងារបច្ចុប្បន្នៈ វរសេនីយ៍ឯក,

នាយការិយាល័យប្រតិបត្តិការសឹករងបញ្ជាការដ្ឋានបញ្ជូនសារអគ្គបញ្ជាការ

ស្រុកកំណើតនៅភូមិគំរូ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបាត់ដំបង

សព្វថ្ងៃរស់នៅភូមិគំរូ ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៥៩:៤១

៣២ទំព័រ

ធានី ៖ ថ្ងៃនេះថ្ងៃទី១០ ខែ១២ ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជាលោកពូ ។

សារ៉ាន ៖ បាទៗ ។

ធានី ៖ ខ្ញុំមកនេះគ្រាន់ចង់សាកសួរលោកពូ ទាក់ទងនឹងប្រវត្តិរបស់លោកពូ ដែលពូបានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥឡូវ ។
ហើយប្រវត្តិទាំងនេះពួកខ្ញុំសុំអនុញ្ញាតិយកទៅសរសេរជាសៀវភៅ
ក៏ដូចជាសម្រាប់អ្នកសិក្សាស្រាវជ្រាវ ដូចក្មេងៗបានដឹងយល់ពីការរស់នៅ ជីវភាពរបស់ប្រជាជន ឬក៏អ្នកតស៊ូក្នុងសម័យមុនៗណា៎ ។

សារ៉ាន ៖ បាទៗ ។

ធានី ៖ ហើយខ្ញុំសុំអនុញ្ញាតិពូ សុំថតជាសម្លេង ក៏ដូចជារូបអីចឹងបានទេ?

សារ៉ាន ៖ ថតជារូប ។

ធានី ៖ ថតជារូបថត?

សារ៉ាន ៖ អត់មានបញ្ហាអីទេ ព្រោះខ្ញុំជាកងទ័ពៗ ។

ធានី ៖ ចឹងពូមានឈ្មោះអីដែរ?

សារ៉ាន ៖ ខ្ញុំអី! តាមពិតខ្ញុំឈ្មោះ ដោក សារ៉ាន ។

ធានី ៖ ដោក សារ៉ាន់?

សារ៉ាន ៖ បាទ!

ធានី ៖   ចឹងឈ្មោះពូសព្វថ្ងៃ ឈ្មោះអីគេ?

សារ៉ាន ៖ ដល់ខ្ញុំចូលកងទ័ពទៅជាឈ្មោះ ដោក សារ៉ាំវិញ ។

ធានី ៖   ដោក សារ៉ាំ ចឹងនោះពូ?

សារ៉ាន ៖ បាទៗ ។

ធានី ៖   អត់មានឈ្មោះបដិវត្តអីទេ?

សារ៉ាន ៖ អត់មានអីទេ មានតែប៉ុនហ្នឹង ។

ធានី ៖   ពូឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

សារ៉ាន ៖ ខ្ញុំអឺ! នេះអាយុ៥១ឆ្នាំហើយ ។

ធានី ៖   ពូមានស្រុកកំណើតនៅណាដែរ?

សារ៉ាន ៖ នៅភូមិគំរូ ។

ធានី ៖   ស្រុកកំណើតភូមិគំរូ ឃុំអីដែរ?

សារ៉ាន ៖ អឺ! ឃុំថ្មពួក ។

ធានី ៖   ស្រុក?

សារ៉ាន ៖ ស្រុកថ្មពួក ខេត្តបាត់ដំបង អាហ្នឹងយើងនិយាយពីស្រុកកំណើត ។

ធានី ៖   តែដល់ពេលសព្វថ្ងៃ?

សារ៉ាន ៖ បន្ទាយមានជ័យ ។

ធានី ៖   សព្វថ្ងៃនៅភូមិគំរូដដែល?

សារ៉ាន ៖ នៅភូមិគំរូ ។

ធានី ៖   គ្រាន់តែគេដូរពី?

សារ៉ាន ៖ បាទ! ភូមិគំរូ ឃុំគំរូទៀត ។

ធានី ៖   ភូមិគំរូ ឃុំគំរូ?

សារ៉ាន ៖ បាទ!

ធានី ៖   ដល់ពេលស្រុក?

សារ៉ាន ៖ ស្រុកថ្មពួក ។

ធានី ៖   ស្រុកដដែល ថ្មពួក?

សារ៉ាន ៖ ខេត្តបន្ទាយមានជ័យ ។

ធានី ៖   ដូរខេត្ត?

សារ៉ាន ៖ បាទៗ អាគេបំបែក អាខេត្តហ្នឹងពីដើមវាជាខេត្តចំណុះជាមួយគ្នា ដល់ចឹងគេដូរទៅចេញ បន្ទាយ បំបែកជាពីរ ។

ធានី ៖ បំបែកពេលណាដែរពូ ខេត្តបន្ទាយមានជ័យហ្នឹង?

សារ៉ាន ៖ ខ្ញុំដូចចាំអត់បាន វាខ្ទង់ឆ្នាំដូច៨០ ៨០ជាងអី ប្រហែលជាខ្ទង់ ខ្ញុំអត់ចាំទេអាហ្នឹង ប្រហែលជាខ្ទង់៨០ៗឡើង ព្រោះ៨០ឡើងមកដល់នេះយើងបំបែកខ្ទង់៨៥ ៨៦ក៏មិនដឹង តែបើចង់ច្បាស់ចាំសួរគេខាងស្រុកគេបានកត់ត្រាទុក ព្រោះខ្ញុំធ្វើញកងទ័ពតាំងពីឆ្នាំ៨០ ខ្ញុំចូលទៅនៅខាងក្នុង ។

ធានី ៖ ចឹងមុនហ្នឹង ពូធ្វើអីគេទៅ?

សារ៉ាន ៖ និយាយរួម បើនិយាយពីប្រវត្តិពីមុនមកគឺ ចង់ឲ្យខ្ញុំនិយាយពីឆ្នាំអី!ពីសង្គមមក?

ធានី ៖ ពីដំបូង ចា៎!

សារ៉ាន ៖ ពីដំបូងមកគឺឆ្នាំលន់ នល់ គឺខ្ញុំបានរៀននៅសាលាបឋមសិក្សាថ្មពួកហ្នឹង ហើយរហូតដល់៧៥ហ្នឹងបានរំដោះ ពួកនៅខាងកម្ពុជាប្រជាធិបតេយ្យបានរំដោះ ។ ហើយខ្ញុំក្នុងនោះខ្ញុំបានជម្លៀសឲ្យទៅនៅគោកកបិន ប៉ុននៅស្រុកហ្នឹង គោកកបិន ឃុំផ្គាំ ស្រុកថ្មពួកដដែល ។ រហូតដល់ឆ្នាំ៧៩ ។

ធានី ៖ ម៉េចទៀតពូ?

សារ៉ាន ៖ ៧៩ហ្នឹងបាន បើចង់និយាយការលំបាកនៅក្នុងប៉ុលពត ខ្ញុំនិយាយប្រាប់បាន ប៉ុន្តែគ្រាន់ថានិយាយត្រួសៗ ខ្ញុំគ្រាន់និយាយថា ពីឆ្នាំ៧៥ដល់៧៩ហ្នឹងខ្ញុំបាន ពួកខ្មែរក្រហមជម្លៀសខ្ញុំទៅនៅហ្នឹង ជម្លៀសទៅនៅខាងភូមិគោកកបិន ឃុំផ្គាំ ស្រុកថ្មពួក ។ ដល់៧៩ខ្ញុំបានវិលត្រឡប់មកស្រុក មកភូមិឃុំខ្ញុំខាងលើមិញ ភូមិគំរូ ឃុំគំរូ ស្រុកថ្មពួក ខេត្តបាត់ដំបងហ្នឹង ។ រហូតដល់ឆ្នាំ៨០ៗ គឺខ្ញុំបានចូលបម្រើកងទ័ពរដ្ឋកម្ពុជាៗប្រជាមានិតកន្លងមកហ្នឹង រហូតដល់បច្ចុប្បន្នហ្នឹង ។ ហើយចង់សួរម៉េចទៀត សួរមកចុះ ។

ធានី ៖ ចឹងចង់សួរពូបកក្រោយវិញថា ពេលពូចូលរៀននៅសាលារៀនថ្មពួកហ្នឹង រៀនថ្នាក់ទីប៉ុន្មានដែរ?

សារ៉ាន ៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ទេ! ៧ពីដើម៧ចាស់ ហើយដោយសារពួកខ្មែរក្រហមរំដោះមក វាក៏បានបញ្ឈប់ខ្ញុំនៅឆ្នាំ នៅខែ៤គេហៅស្អីបង? ហ៎!១៧មេសាហ្នឹង ឆ្នាំ៧៥ហ្នឹង ហើយបានរំដោះ ក៏វាឈប់ឲ្យខ្ញុំរៀនរហូតហ្នឹង ។ ហើយក៏បានជម្លៀសខ្ញុំចេញទៅនៅខាងដូចខ្ញុំរៀបរាប់ខាងលើហ្នឹង ។

ធានី ៖ ចឹងបានន័យថាពូរៀនសម័យលន់ នល់តាំងពីឆ្នាំ១៩៧០ ដល់១៩៧៥?

សារ៉ាន ៖ បាទៗ រៀនបានតិចតួចទេ ជំនាន់ហ្នឹងដូចជីងស្រាប់ហើយ ផ្នែកជីវភាពរបស់ មិនមែនជីវភាពវាមិនលំបាកប៉ុន្មានទេ ដោយសារតែពីមុនវាមិនសូវមានអ្នកណាសូវជំរុញ ហើយរៀនក៏រៀនទៅ មិនរៀនៗទៅចេះដល់អាយុធំរហូតដល់១២ឆ្នាំ ហើយបានចូលរៀនៗ ដូច្នេះ បានរៀនតិចណាស់ៗ ប៉ុន្តែបើសិនមិនមានរបបខ្មែរក្រហម ចូលមកប្រហែលជាខ្ញុំបានឆ្លងកាត់ទៅអនុវិទ្យាល័យអីដែរ មិនត្រឹមទី៧ហ្នឹងទេ អាចឆ្លងទៅទៀតៗ ប៉ុន្តែវាមិនធម្មតា ដោយសាររបបនេះអត់មានសាលារៀន គេឈប់ៗ

ធានី ៖ ចឹងពេលរៀនហ្នឹង ពូជួបប្រទះការលំបាកអីខ្លះទៅពូ?

សារ៉ាន ៖ កាលពីខ្ញុំ អន្តាល់រៀនហ្នឹងវាជួបប្រទះការលំបាកដូចជាធម្មតាទេ កាលជំនាន់មុនវាគ្មានរីកចំរើនផ្នែកសាលារៀនអី រៀនតែព្រឹកៗខានល្ងាចៗ រៀនព្រឹកៗទេ ហើយការបង្រៀនហ្នឹងក៏អារឿងជីវភាពគ្រួសារវាមានជួបការលំបាកៗ វាដូចជាសៀវភៅ ប៊ិចសរសេរអី គឺមានការខ្វះខាតច្រើន សំលៀកបំពាក់អីហ្នឹងៗ ប៉ុន្តែ ធម្មតាទេ កាលហ្នឹងប្រហាក់ប្រហែលតែគ្នាហ្នឹងៗ

ធានី ៖ ចុះគ្រូអីម៉េចដែរ?

សារ៉ាន ៖ គ្រូកាលហ្នឹងនិយាយពីរឿងគ្រូ គុណភាពគ្រូ បើយើងនិយាយពីគុណភាពគ្រូហ្នឹង គឺមានគុណភាពល្អគ្រូៗ បើយើងប្រៀបធៀបនៅសម័យហ្នឹង ខ្ញុំមិនហ៊ានថានេះទេ ប៉ុន្តែគ្រូកាលហ្នឹងរៀនមិនលក់ក្រដាសលក់អីដូចសព្វថ្ងៃនេះទេៗ សព្វថ្ងៃនេះថាប្រាក់ខែក៏តិចដងអីដង រៀនមានបញ្ហាជួបជីវភាពគ្រួសារ ក៏ចេះមានបញ្ហា រៀនគួរខ្លះ ឬក៏រៀនមិនគ្រប់ម៉ោង តាមខ្ញុំយល់សព្វថ្ងៃៗ ប៉ុន្តែ ដល់ខ្ញុំរៀនកន្លងមកឆ្នាំពី៧០ដល់៧៥ហ្នឹង ទោះបីរៀនមិនបានព្រឹកល្ងាចមែន តែការរៀនរបស់គ្រូ គឺឧទាហរណ៍ថាម៉ោង៧ដល់ម៉ោង១១ គឺដឹងថាម៉ោង១១អត់មានរហេតរហូតទេៗ ហើយវិន័យកូនសិស្សក៏តឹងរឹង ហើយកូនសិស្ស បានន័យថាកូនសិស្សជំនាន់ហ្នឹងស្តាប់គ្រូ ខ្លាចគ្រូ អត់មានដូចសព្វថ្ងៃទេ ព្រោះគ្រូពីដើមវៃ បើគ្រូសព្វថ្ងៃវៃអត់បានទេៗ

ធានី ៖ វៃ ឲ្យម៉ែវៃវិញ?

សារ៉ាន ៖ បើគ្រូពីដើម ដាក់ឯងទាល់តែបែកខ្នង បែកសាច់បែកអីខ្លះដែរ ប៉ុនសព្វថ្ងៃនេះ ខ្ញុំមើលទៅគ្រូមិនសូវជាហ៊ានវៃគ្រូទេៗ ប៉ុនបើសិនយើងវៃហួសហេតុពេក វាបញ្ហាគេថាសិទ្ធិគេ សិទ្ធិមនុស្សសិទ្ធិអីគេហ្នឹង គេថាវៃអីគេណា ខ្ញុំដឹងតែប៉ុនហ្នឹងៗ

ធានី ៖ ចឹងពេលពូរៀនហ្នឹង មានគេទម្លាក់គ្រាប់បែកអីទេ?

សារ៉ាន ៖ អឺ! តំបន់នេះ បើខ្ញុំកើតមកហ្នឹង ខ្ញុំជួបប្រទះនៅកន្លែងគេវៃបន្ទាយទេក្នុងសាលាហ្នឹង ហើយវៃ២-៣ដងដែរ ហើយស្លាប់មនុស្សស្លាប់អីមិនដឹងចំនួនប៉ុន្មានទេ ប៉ុនវៃបន្ទាយយើងនេះអាបៀតផ្សារនេះ គេវៃគ្នាខ្លាំងដែរ ។

ធានី ៖ គេហៅបន្ទាយអីគេ?

សារ៉ាន ៖ គេហៅថាបន្ទាយស៊ប់ៗថ្មពូក គេហៅបន្ទាយថ្មពូកហ្នឹង បន្ទាយធំដែរ និយាយរួមកាលហ្នឹងប្រឡងពីដើមគេហៅអនុខេត្ត អាកន្លែងហ្នឹង ។ ដូច្នេះ គេហៅស៊ប់ហ្នឹងខាងយោធាគេមកគ្រប់គ្រង ខ្មែរក្រហមវាវៃរហូតទល់ទីផ្សារហ្នឹង ហើយស្លាប់មនុស្សស្លាប់អីដែរជិតនាន់ហ្នឹង ។

ធានី ៖ ចឹងពេល៧៥ហ្នឹង ខ្មែរក្រហមវៃបែកហ្នឹង ដែលពូបានឃើញរឿងដែលគេវៃបន្ទាយបែកហ្នឹងឃើញមនុស្សស្លាប់ហ្នឹង?

សារ៉ាន ៖ ឃើញៗ បាទ!ឃើញរហូតដល់គេបាញ់ស្លាប់ម៉ាជួរអីចឹងទៅ ហើយរហូតដែលចូលមកដល់វិញ ។ ខ្ញុំកាលហ្នឹង ខ្ញុំទៅរៀន កូនគាអីកូនគា យាយឡុំ គាត់ជិះម៉ូតូពួកមាត់សាមោមហ្នឹង ពួកខ្មែរក្រហមនៅចាំពួកទាហានលន់ នល់ហ្នឹង ដល់ពេលទៅដល់ជិះម៉ូតូទៅដល់គេបាញ់គេបាញ់ផាប់នោះបៀតសាលារៀនហ្នឹង អាហ្នឹងខ្ញុំឃើញតែប៉ុនហ្នឹងទេ ។ ដោយឡែកពួកបញ្ហាដែលស្លាប់ខាងក្រៅៗ ខ្ញុំមិនបានដឹងទេ ប៉ុន្តែតាមឪពុកម្ដាយដែលគាត់ថា ពួកខ្មែរក្រហមស្លាប់អស់ច្រើនណាស់ ពួកដែលបានវៃមកហ្នឹង ពួកខាងទាហានលន់ នល់ គេមានលទ្ធភាពច្រើនជាងៗម៉េច ដោយសារគេមានគ្រាប់បែក គ្រាប់រំសេវ គ្រាប់បេអឺៗហ្នឹងគេទំនើបណាស់ខាងខ្មែរ ខាងលន់ នល់ ។ ដោយឡែកខាងខ្មែរក្រហមនឹងគឺគ្រាប់ម៉ាសំពាយៗមកទេ ។ ដូច្នេះចូលមកចំកន្លែងចំនុចរបស់គេ ដែលមានគេត្រៀមចាំហ្នឹងគឺ ស្លាប់អស់ច្រើនណាស់ ។

ធានី ៖ ប៉ុន្តែចុងក្រោយខ្មែរក្រហមឈ្នះដដែល?

សារ៉ាន ៖ អាហ្នឹង ដោយសារឈ្នះគឺអាហ្នឹងមូលហេតុខាងលើខ្ញុំមិនដឹងទេ តែបើតំបន់នេះ គឺវៃអត់បែកទេ ។ វៃបានម៉ាចូលតាមស្រុកហ្នឹង អាបន្ទាយនេះវៃអត់បានទេ ។

ធានី ៖ ចឹងពូ?

សារ៉ាន ៖ បាទ!

ធានី ៖ ចឹងពេលដែលពូបានឃើញហ្នឹង គឺខ្មែរក្រហមអត់បានកាន់កាប់ទេ ពេលចូលមកដល់គេវៃ?

សារ៉ាន ៖ អត់ទេ វៃរួចបានន័យថាបរាជ័យ រហូតដល់ឆ្នាំដូចខ្ញុំថា១៧មេសា បានបែកមកពីលើចឹងខាងនេះទម្លាក់អាវុធ ពព្រោងពព្រោតតាមតែមេពីហ្នឹងទៅ ខ្លះក៏រត់ចូលទៅដីថៃទៅ អានេះខ្ញុំ

បានដឹង គឺកន្លែងនេះវៃអត់បែកទេ ដោយសារតែមកពីលើដាក់ទង់សចុះចាញ់ លន់ នល់ណា ដូច្នេះទាហានមួយចំនួន ។

ធានី : ចឹងតាមពិតទាហានហ្នឹងមិនមែនខ្មែរក្រហមវៃបែកទេ គឺយើងចុះចាញ់គេ?

សាវ៉ាន : យើងចុះចាញ់ ដោយសារចុះចាញ់ពីលើ បើកន្លែងនេះតាមពិតខ្មែរក្រហមធ្វើអត់បានទេបាន ន័យថានៅឈ្នះរឹងមាំ ដោយសារខាងនោះបញ្ជាទម្លាក់អាវុធ ខ្វះ ។

ធានី : ខាងណា?

សាវ៉ាន : ខាងលន់ នល់ៗចុះចាញ់ ។

ធានី : លន់ នល់ប្រាប់ថាចុះចាញ់?

សាវ៉ាន : បាទ! ចុះបើបរាជ័យនៅក្បាលម៉ាស៊ីនហើយ គេវៃនោះបានហើយ រឿងអីអាមែកធាងនេះបានទៀត ។

ធានី : ចឹងបានន័យថា ១៧មេសាហ្នឹង ខ្មែរក្រហមចូលដល់ភ្នំពេញភ្លាមខាងនេះចុះចាញ់ភ្លាម?

សាវ៉ាន : ខាងហ្នឹងចុះចាញ់ ចឹងបានខ្ញុំរៀនរហូតដល់ពេលខ្មែរក្រហមចូលមកឈប់ឲ្យរៀន ។ ហើយខាងទាហានមួយចំនួនដែលមិនពេញចិត្ត គេដឹងខ្លួនគេរត់តាមផ្លូវហ្នឹងទៅ ចូលដីថៃ ខ្វះដែលនៅចុងបំផុតដូចពុកខ្ញុំធ្វើទពដែរ រហូតដល់គេស្រាវជ្រាវ ដឹងថាយើងធ្វើទពបម្រើខាងលន់ នល់ចឹងក៏គេអត់ឲ្យនៅភូមិស្រុកហ្នឹងទេ ។ ផ្ទះខ្ញុំនៅនោះ នោបៀតត្រង់ហ្នឹង ដល់នេះគេជម្លៀសអ្នកទាហាន អ្នកជាប់និន្នាការទាហានមួយចំនួន គេឲ្យទៅជម្លៀសចេញពីហ្នឹង គេថាខ្លាចលំ មានគ្រាប់បែកឡោងអីណា អាហ្នឹងជាលេសរបស់គេទេ ។ អានេះខ្ញុំដឹងប៉ុនហ្នឹង ពីឆ្នាំហ្នឹងណា៎ ។

ធានី : ចឹងពេលដែលពូចូលដល់ឆ្នាំ៧៥ ពូជម្លៀសទៅខាងផ្កាំ ទៅខាងគោកកបិន?

សាវ៉ាន : បាទ! នៅគោកកបិន ឃុំផ្កាំ ស្រុកថ្មពួកដដែលទេ គ្រាន់តែខុសភូមិ ហើយហ្នឹងសង្កាត់ និងឃុំនិយាយរួមខុសតែប៉ុនហ្នឹងទេ ។

ធានី : នៅភូមិផ្កាំ ឃុំគោកកបិន?

សាវ៉ាន : អឺ!ភូមិផ្កាំ អឺ!សុំទោសអឺ! ភូមិគោកកបិន ឃុំផ្កាំ ស្រុកថ្មពួក ប៉ុនខេត្តបាត់ដំបង ។

ធានី : ភូមិគោកកបិន?

សាវ៉ាន : បាទ! ភូមិយើងនេះចុះទៅប្រហែលខ្ទង់១០គីឡូជាង ។

ធានី : ចង់សួរពូថា ដំបូងពេលខ្មែរក្រហមមកដល់យ៉ាងម៉េចខ្វះដែរ ទិដ្ឋភាពពេលហ្នឹង ពេលចូលមកដល់ភូមិយើង មកដល់ភ្លាមគេធ្វើម៉េចខ្វះ?

សារ៉ាន ៖ ទិដ្ឋភាពដែលចូលមកដល់ហ្នឹង ដែលខ្ញុំបានដឹង ការចូលមកដល់ខាងទាហានដែលខាងហ្នឹង ខាងទាហានលន់ នល់ គេបានស្វាគមន៍គ្នាទៅវិញទៅមក អាហ្នឹងការទំនាក់ទំនងចាប់ដៃគ្នាទៅវិញទៅមកហ្នឹង គឺដូចជាមិនមានបញ្ហាអីទាំងអស់ អាហ្នឹងឃើញស្វាគមន៍គ្នាទៅវិញទៅមកទេណ៎ ទៅត្រួតពិនិត្យគ្រាប់បែករំសេវដែលនៅចូលក្នុងបន្ទាយធម្មតាអីចឹងចាប់ដៃ ។ តែដល់ក្រោយរយៈពេលប៉ុន្មាន ម៉ាថ្ងៃពីរថ្ងៃវាមានការប្រែៗ បានន័យថាគេចង់ធ្វើប្រមូលទាហានដែលបម្រើឲ្យលន់ នល់ហ្នឹង គេចាប់សម្លាប់បណ្តើរៗ ។ បានសម្លាប់គ្មានឲ្យប្រជាជនដឹងទេ គឺគេបញ្ជូនទៅ នេះទៅនោះ បញ្ជូនខ្លះដូចពុកខ្ញុំជម្លៀសទៅខាងផ្គាំ ខ្លះជម្លៀសទៅផុត ខ្លះគេដឹកយកទៅណា សម្លាប់ចោលឆ្ងាយៗ អាហ្នឹងខ្ញុំមិនដឹងសម្លាប់នៅណាទេ ។ ប៉ុនមុនដំបូងមិនអីទេ គេបានន័យថា គេរាក់ទាក់ណា តែក្រោយមកក៏គេប្រើល្បិចអីផ្សេងៗ ។

ធានី ៖ ចឹងពូដឹងថាហេតុអីបានពូត្រូវជម្លៀសចេញពីភូមិហ្នឹងទៀត?

សារ៉ាន ៖ ជម្លៀសដោយសារខ្ញុំជាប់និន្នាការឪពុកម្តាយ ឪពុកខ្ញុំធ្វើទាហាន ។

ធានី ៖ ពេលហ្នឹងពូទៅជាមួយឪពុកពូទេ?

សារ៉ាន ៖ បាទ! ខ្ញុំទៅដែរ ទៅទាំងគ្រួសារទាំងអស់ ។

ធានី ៖ ចុះអ្នកផ្សេងទៀត?

សារ៉ាន ៖ អ្នកផ្សេងៗអត់ទេ ដែលអ្នកនិយាយរួមនៅក្នុងភូមិនេះអ្នកណាដែលពាក់ព័ន្ធបម្រើទាហានលន់ នល់ ណាគេឲ្យទៅទាំងអស់ ។

ធានី ៖ អូ! ពាក់ព័ន្ធនឹងរាជការ?

សារ៉ាន ៖ បាទ! ឲ្យតែពាក់ព័ន្ធនឹងរាជការ និយាយរួមឲ្យតែពាក់ព័ន្ធផ្នែករាជការ គឺគេប្រមូលទៅហើយ អត់មានទុកទេ ។ ហើយដោយឡែកអ្នកដែលមិនពាក់ព័ន្ធឲ្យនៅនេះ ដូចខ្ញុំចឹងគេជម្លៀសចេញ គេខ្លាចយើងស៊ើរើ មានកាំភ្លើងអីបាញ់ពួកវា ។ អាហ្នឹងដែលខ្ញុំគំនិតគិតឃើញចឹង ព្រោះបើសិនឲ្យនៅហ្នឹង វាមិនទុកចិត្តយើង ។

ធានី ៖ ចា៎! ដល់ពេលជម្លៀសគេប្រាប់ថាម៉េចខ្លះ?

សារ៉ាន ៖ គេថា និយាយរួមខ្ញុំក្តាប់អត់បាន គេឲ្យតែគេឲ្យចេញចេះចេញតាមគេ ។

ធានី ៖ មានប្រាប់ប៉ុន្មានថ្ងៃ?

សារ៉ាន ៖ បាទ! អត់ទេ អត់មានប្រាប់ប៉ុន្មានថ្ងៃទេ ។

ធានី ៖ តែយើងយកអីខ្លះទៅ?

សារ៉ាន ៖ យករបស់ណាដែលយើងយកបាន ដូចជារបស់ហូបចុកប្រចាំថ្ងៃទៅណាយើង យកបានប៉ុន ណាយកប៉ុនហ្នឹង ហើយផ្ទះទុកចោលទៅ ។ ហើយចឹងបានថា អាហ្នឹងខ្ញុំគ្រាន់ដឹងថា មិនដឹងជា គេគោលបំណង ដល់ក្រោយមកខ្ញុំដឹងថា ពួកហ្នឹងវាមិនចង់ឲ្យទាហាននៅទីរួមស្រុកទុកចឹងណា វាជម្លៀសចេញផុតទៅ ដើម្បីវាប្រើវិធីអីផ្សេងៗខ្ញុំមិនដឹងទេ ព្រោះវាអត់ទុកចិត្តទាហាន ព្រោះខ្លាចលួចមានកប់គ្រាប់អីត្រង់ណាផ្សេងៗ ធ្វើម៉េចទៅវាខ្លាចចឹង ។ នេះគំនិតខ្ញុំដឹង ពុកខ្ញុំ គាត់និយាយប្រាប់ថា ។

ធានី ៖ ពុកប្រាប់ចឹង?

សារ៉ាន ៖ បាទ! ពុកថា *"ពួកអាហ្នឹងវាអត់ទុកយើងឲ្យរួមស្រុកអីទេ វាជម្លៀសយើងឆ្ងាយដើម្បីមានវិធាន ការណ៍អីផ្សេងៗ"* អាហ្នឹងខ្ញុំដឹងតែប៉ុនហ្នឹង ព្រោះខ្ញុំនៅតូចដែរកាលហ្នឹង ។ អាយុទើប១៧ ១៦ តែប៉ុនហ្នឹងទេ ។

ធានី ៖ ព្រោះពូអាយុ៥១?

សារ៉ាន ៖ បាទៗ ។

ធានី ៖ ហើយចឹងពូដល់ពេល ពូជម្លៀសទៅហ្នឹង ដឹងថាអ្នកណាគេអ្នកបញ្ជាឲ្យជម្លៀសចេញទេ អ្នក ភូមិយើង?

សារ៉ាន ៖ ខ្ញុំការបញ្ជាហ្នឹង ប្រហែលជាខ្ញុំគ្រាន់ស្មានថា មិនមែនត្រឹមថ្នាក់ស្រុកថ្នាក់ខេត្តទេ អានេះ ប្រហែលជាផែនការគោលរបស់វា របស់មេធំពីលើមក ឲ្យតែតំបន់ទីរួមស្រុក ទីរួមខេត្តគឺ ដែលមានពាក់ព័ន្ធ ដែលទាហានប្រឆាំងពួកខ្មែរក្រហម គឺត្រូវតែផែនការមិនមែនត្រឹមថ្នាក់ទេ ខ្ញុំថាផែនការមកពីលើម៉ង ។ ព្រោះមិនមែនតែស្រុកហ្នឹងទេ ស្រុកណាក៏ដោយគេត្រូវជម្លៀស សូម្បីតែអ្នកទៅនៅភ្នំពេញក៏ដោយ គឺត្រូវជម្លៀសចេញ ។ ហើយណាមួយដែលខ្ញុំដឹងកន្លងមក ហ្នឹង អ្នកដែលនៅទីរួមខេត្តក្រុងហ្នឹង មានយោបល់មួយថា សូមឲ្យអ្នកចេញឲ្យផុតចឹងណា ឲ្យ ផុតទីប្រជុំជនខ្លាចអាមេរិចកាំងទម្លាក់គ្រាប់បែក ។

ធានី ៖ អូ! គេនិយាយចឹង?

សារ៉ាន ៖ ហ្នឹងហើយ គេខ្លាចអាមេរិចកាំងទម្លាក់គ្រាប់បែក ដូច្នេះខ្ញុំក៏ចេញអាហ្នឹងខ្ញុំដឹង គេមិនមែនផែន ការថ្នាក់តូចតាចទេ គឺផែនការមេគោលការណ៍របស់វាពីលើមកម៉ងចឹងម៉ង ។

ធានី ៖ ចឹងការពេលពូជម្លៀសទៅហ្នឹង ទៅប៉ុន្មានគ្រួសារដែរ?

សាភ៉ន ៖ និយាយរួមខ្ញុំក្តាប់មិនបានអស់ទេ ព្រោះឲ្យតែទាហានដែលខ្ញុំបានទៅរួមរស់ក្នុងគ្រួសារហ្នឹងក្នុង នេះប្រហែលជា៨-១០-២០គ្រួសារហ្នឹង។

ធានី ៖ ចា៎! ម៉ាភូមិហ្នឹង៨-១០គ្រួសារ?

សាភ៉ន ៖ ៨-១០ហ្នឹង ដែលទៅជួបជុំគ្នានោះបានច្រើនខ្ញុំក្តាប់អត់បានទេ។

ធានី ៖ ចឹងអ្នកដែលជម្លៀសទៅភូមិគោកកឋិនទាំងអស់ហ្នឹង គឺសុទ្ធតែអ្នកទាហាន ហើយនឹងទាហានជាប់និន្នាការទាំងអស់?

សាភ៉ន ៖ ទាហានជាប់និន្នាការរបស់លន់ នល់។

ធានី ៖ អត់មានអ្នកស្រុកភូមិយើងនៅហ្នឹង?

សាភ៉ន ៖ អត់មានទេ ប៉ុនចេះមានពួកគេជម្លៀសចេញពីភ្នំពេញមកៗភ្នំពេញដូចជាមិនមែនភ្នំពេញសុទ្ធ ទាំងអស់ទេ ខេត្តតាកែវ ខេត្តកំពត កំពង់ស្ពឺ។

ធានី ៖ មានទៅដល់ហើយ?

សាភ៉ន ៖ បាទៗ មានគេជម្លៀសឲ្យតែអ្នកមានគេជម្លៀស ឲ្យតែអ្នកដូចខ្ញុំនិយាយចឹង ឲ្យតែពាក់ព័ន្ធ ពីកន្លែងណាពាក់ព័ន្ធធ្វើបម្រើឲ្យលន់ នល់គឺត្រូវតែជម្លៀសមកម៉ង។

ធានី ៖ ឆ្នាំ៧៥ ថ្ងៃ១៧ មេសាហ្នឹង?

សាភ៉ន ៖ ហ្នឹងហើយជម្លៀស វា។

ធានី ៖ ទាន់ទេពូ?

សាភ៉ន ៖ វាមិនដល់ឆ្នាំ ប្រហែលជាខ្ទង់ខែ៥ខែអីទេ ព្រោះយើងរំដោះ១៧មេសា។

ធានី ៖ ១៧មេសា ចា៎!

សាភ៉ន ៖ ប៉ុន្តែដល់ក្រោយមក ទាំងខែ៥ ខែ៦ ខែ៧ គេជម្លៀសបណ្តើរៗមក។

ធានី ៖ អូ! ទៅប្រជុំគ្នានៅគោកកឋិន?

សាភ៉ន ៖ បាទ! ទៅជួបគ្នាសួរៗសុទ្ធតែអ្នកគេហៅអ្នកជម្លៀសគេហៅពួកអ្នក១៧មេសា ពួកដល់ចុងក្រោយគេថាសុទ្ធតែពួកមូលធនគេនោះ ពួកគេនិយាយណា៎។ ពួកដែលមូលដ្ឋានគេរស់នៅគេថាពួកអាមូលធន ពួកអាបម្រើនពួកលន់ នល់ ពួកអាម៉ែន ពួកអាអ្នកមាន។

ធានី ៖ ម៉ែនហ្នឹងវាម៉េច?

សាភ៉ន ៖ ពួកអាម៉ែនហ្នឹង ចង់និយាយថា ពួកអាទាហានលន់ នល់ហ្នឹង វាវៃថាអាម៉ែនៗខ្ញុំមិនដឹងថាភាសាវាម៉េច អាម៉ែនអាវៃជ្រូកក៏ថាអាម៉ែន អាវៃអាម៉ែនស៊ី។ ដល់ចឹងអាអ្នកនៅរស់ចេះពុថាវៃអាម៉ែនៗខ្លាចតែវៃមនុស្សខ្លាចអាហ្នឹង។ ចឹងបានថាខ្ញុំដឹងតែប៉ុនហ្នឹង។

ធានី ៖ ចឹងពេលពូជម្លៀសទៅហ្នឹងនៅមុនក្រោយ១៧មេសាហ្នឹង បានពូជម្លៀសទៅ៤-១០គ្រួសារ ទៅដល់ហ្នឹងពូធ្វើអីខ្លះ?

សារ៉ាន ៖ ខ្ញុំកាលទៅដល់នោះ ខ្ញុំ១៥-១៦ គឺវាស្ថិតនៅវាដាក់ទៅក្នុងកងចល័ត ។ កងចល័តហ្នឹងគឺបើយើងនិយាយទៅវាអត់ពេញកម្លាំងទេ ព្រោះនៅក្មេងដែរ១៥-១៦នៅខ្ចីណាស់ ។ ហើយខ្ញុំទៅលើកដីវាលំបាកណាស់ ដើម្បីថាគេអ្នកធំៗគេធ្វើបាបខ្ញុំដូចជា គេថាពួកខ្ញុំ១៧មេសា ពួកមូលធន ពួកបម្រើឲ្យលន់ នល់ចឹង ។ ហើយគេយកខ្ញុំដាក់នៅក្នុងកងចល័ត ដោយសារដាក់កងចល័តគឺពួកគេសុទ្ធធំៗទាំងអស់ ហើយគេឲ្យខ្ញុំនៅនឹងទឹកជ្រៅៗចឹងគេបោះអាដុំកដីធំៗបោះឲ្យលើយើងចាប់ យើងចាប់គ្មានបានអី ។

ធានី ៖ ដុំកដីធំៗ យើងនៅទឹកជ្រៅ?

សារ៉ាន ៖ បោះយើងឈរ គេឲ្យយើងឈរឯងទាបឯកក់ ហើយស្មើនឹងទឹកណា ហើយគេកាប់ដីធំៗគេបោះឲ្យយើងចាប់ៗម៉េចដាប់ណា ។

ធានី ៖ កាប់ធ្វើអី?

សារ៉ាន ៖ លើកទំនប់ ។

ធានី ៖ លើកទំនប់នៅក្នុងទឹកហ្នឹង?

សារ៉ាន ៖ បាទ! លើកទំនប់ក្នុងទឹកហ្នឹង ហើយយើងតូចជាងគេ ហើយគេឲ្យនៅក្រោមទៀត គេអ្នកធំគេ បោះទម្លាក់ឲ្យយើងចាប់ៗមិនជាប់ស្អី ហើយចឹងគេប្រមាថមើលងាយសុទ្ធឯស្អីណា ប៉ុនយើង មិនមាត់ទេ ព្រោះដឹងថាយើងឪពុកម្ដាយស្ថិតនៅក្រោមការគ្រប់អាសន្នាត់ដូចថាថ្ងៃណាក៏អាចយកទៅបាន ។ ហើយនេះយើងខំតស៊ូ និយាយរួមខំតស៊ូ ។

ធានី ៖ ហើយចឹងកាលពេលពូទៅលើកដីៗនៅកន្លែងណាទៅ?

សារ៉ាន ៖ លើកដីដែលខ្ញុំជំហានដំបូងនៅឃុំផ្តាំ ។

ធានី ៖ នៅឃុំផ្តាំ នៅកន្លែងណា?

សារ៉ាន ៖ អឺ! ទំនប់ផ្តាំ ។

ធានី ៖ តាម៉េង?

សារ៉ាន ៖ តាម៉េងក៏លើក ផ្តាំក៏លើក ជាពិសេសអាងត្រពាំងថ្មនេះៗជំហានទី២ហើយ បើអានោះលើកឆ្លងស្រុក ។ អានោះខ្ញុំនិយាយរួម៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ខ្ញុំអាងត្រពាំងថ្មខ្ញុំដេកជាប្រចាំតែម្ដង ហើយសុខភាពទ្រុឌទ្រោមណាស់ អត់មានអីហូបទេ ។ អត់មានអីហូបទេ ហូបតែបបរ

ពិបាកណាស់ ខ្ញុំហូបរហូតដល់ធ្លាក់ឈាមពីមាត់ខំប្រឹងប្រែងខ្លាចគេសម្លាប់ណា ។ ហើយរហូតដល់គេស្រណោះ ហើយខ្ញុំខំតស៊ូចឹង គេឲ្យទៅព្យាបាលនៅកន្លែងគេហៅសមរភូមិក្រោយ ។ សមរភូមិក្រោយហ្នឹង គេមានពួកខាងបូព៌ាហ្នឹង គេដូចគេមិនឲ្យយើងដើរទៅណាទេ ប៉ុន្តែគេទុកនៅកន្លែងហ្នឹង គេឲ្យយើងដាំបាយស៊ីខ្លួនយើងទាំងអស់ ចង់ដាំអីដាំទៅមានបាយ ដូចគេបំប៉នសុខភាពយើង ឲ្យយើងហូបមានសាច់ឈាម គេហៅមនុស្សសកម្ម ៗ គេឲ្យយើងទៅហូបកន្លែងហ្នឹងដាំបាយអត់មានអ្នកណាដាំឲ្យទេ ។ ព្រឹកឡើងគេចុះទៅពិនិត្យ ពេទ្យស្អីគេ គេចាក់សុទ្ធតែដប អឺ!គេហៅថ្នាំអាចម៍ទន្សាយហ្នឹង អាដបសុដា ខ្ញុំគ្រាន់តែឃើញអាថ្នាំហ្នឹងមកខ្ញុំចង់រាគនោមបាត់ហើយ វាចាក់ឈឺពេក ។ ខ្ញុំដល់មែនទែនខ្ញុំឈឺ ចង់ជាវិញដោយសារឃើញវាអាដបយើងទឹកក្រូច ។

ធានី ៖ ចាំ! ដបទឹកក្រូច ។

សារ៉ាន ៖ ដបទឹកក្រូចហ្នឹងសុទ្ធទាញសារ៉ាុំងនឹងចាក់ឈឺហាំ ហើយកុំដល់មែនទែន ខ្ញុំជាឯងម៉ងនៅបាន៨ ១០ថ្ងៃសុំគេចេញមកវិញ ។ ហើយការចេញមកវិញ មកដល់ការដ្ឋានហ្នឹងក៏យើងខ្លាចគេដែរ ព្រោះយើងអត់ដូចថាប្រឆាំងហ្នឹងគេថា មិនព្រមនៅឲ្យបានយូរ អាហ្នឹងការខ្ញុំនិយាយប៉ុនហ្នឹងទេ ព្រោះខ្ញុំដឹងតែប៉ុនហ្នឹងការលំបាកដែលខ្ញុំបានឆ្លងកាត់ ។ ខ្ញុំរកដូចចប់ហើយ ។

ធានី ៖ នៅ ៗ ចង់សួរពូថា ពេលដែលពូលើកទំនប់ដំបូង ពូថានៅផ្កាំ ចេញពីផ្កាំមកទៅតាម៉េងសិនតាម៉េងហើយបានទៅត្រពាំងថ្ម?

សារ៉ាន ៖ តាម៉េង គឺត្រពាំងថ្មហ្នឹងគឺជាអចិន្ត្រៃយ៍រហូតដល់ចំនុចមួយចំនួនខ្ញុំផ្លាយដល់ភ្នំស្រុកទៀត គេហៅគល់រំចេក ។

ធានី ៖ គល់រំចេក?

សារ៉ាន ៖ គល់រំចេក ភ្នំស្រុក ។

ធានី ៖ អាហ្នឹងកន្លែងទំនប់គេដែរ?

សារ៉ាន ៖ បាទ! អានោះជីកព្រែកទេ ជីកព្រែកបំបែកពីអាងត្រពាំងថ្មហ្នឹង ។

ធានី ៖ ចឹងចង់សួរពូថា ពូទៅផ្កាំលើកទំនប់ផ្កាំដំបូងលើកឆ្នាំប៉ុន្មាន ៧៥ហ្នឹង?

សារ៉ាន ៖ ឆ្នាំ៧៥ អឺ ៗ៧៥ហ្នឹងហើយ ចុងហ្នឹង ៧៥ ។

ធានី ៖ ៧៥ បន្ទាប់មកទៀត ពូទៅលើកនៅអាងតាម៉េងឆ្នាំប៉ុន្មាន?

សារ៉ាន ៖ អឺ! ខ្ទង់៧៧ ។

ធានី ៖ ១៩៧៧?

សារ៉ាន ៖ បាទៗ ។

ធានី ៖ ៧៧អានតាម៉េង?

សារ៉ាន ៖ អានតាម៉េង ។

ធានី ៖ ចឹងនៅផ្ដាំប៉ុន្មានឆ្នាំ ២ឆ្នាំ ៣ឆ្នាំ?

សារ៉ាន ៖ តាមពិតអានផ្ដាំហ្នឹងយើងមិនបានលើករយៈពេលយូរទេ យើងលើកខ្ទង់ម៉ាខែឬ២ខែ ប៉ុន្តែការ ដែលពួកខ្ញុំ ម៉េចគេហៅកងចល័ត ឧទាហរណ៍ថាលើកបានម៉ាកន្លែងល្មមចឹង កន្លែងណាដែល មានការលំបាកយើងទៅទៀត ។

ធានី ៖ ចាំ! កងចល័ត?

សារ៉ាន ៖ បាទ! កងចល័តទៅមកៗតាម៉េងផង និយាយរួមវាអត់កំណត់ទីណាចប់ ពីតាម៉េងក្នុងអានផ្ដាំ ហើយដែលមូលដ្ឋានសំខាន់បំផុតគឺត្រពាំងថ្មនឹងហើយ ។

ធានី ៖ ត្រពាំងថ្មនៅឆ្នាំប៉ុន្មាន?

សារ៉ាន ៖ ត្រពាំងថ្មហ្នឹង គឺខ្ទង់ម៉ាឆ្នាំទៅមុន ។

ធានី ៖ ម៉ាឆ្នាំទៅមុន?

សារ៉ាន ៖ ទៅមុនចឹង មកវិញចឹងចូលទៀត ។

ធានី ៖ ម៉ាឆ្នាំទៅមុនហ្នឹងពេលណាដែរ?

សារ៉ាន ៖ ទៅអាពេលនេះ អាពេលយើង ខែប្រាំងយើងនេះ ខែច្រូតនេះ ។

ធានី ៖ ខែច្រូតពូទៅត្រពាំងថ្ម ចឹងត្រពាំងថ្មកសាងឆ្នាំប៉ុន្មាន?

សារ៉ាន ៖ អាហ្នឹងបើតាមប្រហែល៧៥ ៧៦ និយាយរួមត្រពាំងថ្មហ្នឹង និយាយរួមថា៧៦ចុះខ្ញុំថា៧៦

ធានី ៖ ចាំ! ១៩៧៦ ខែប្រាំងពូទៅធ្វើហើយ?

សារ៉ាន ៖ បាទ! វាកាលយើងកាលនោះមិនអាចចាំបានទេ ព្រោះយើងគ្មានអីកត់ត្រា ។

ធានី ៖ ចាំៗយើងស្មាន ។

សារ៉ាន ៖ អត់មានអីទេ ស្មានហ្នឹង ហើយការលើកហ្នឹងម៉ារដូវ ខែនេះមកវិញ ខែវស្សាមកវិញ ។

ធានី ៖ ចាំ! ខែវស្សា?

សារ៉ាន ៖ ហើយខែវស្សាទៅវិញ ។

ធានី ៖ ចឹងខែវស្សាពូទៅណាវិញ?

សារ៉ាន ៖ ខែវស្សា ជួនកាលត្រឡប់មកវិញ មកក្រោយវិញ ។

ធានី ៖ អូ! មកផ្ដាំ មកអី?

សាវ៉ាន ៖ អឺ!មកផ្កាំ ។

ធានី ៖ ធ្វើអីគេទៅ?

សាវ៉ាន ៖ មកផ្កាំ គឺលើកទំនប់តូចៗ ។

ធានី ៖ អូ! លើកទំនប់ទប់ភ្លឺស្រែអីចឹង?

សាវ៉ាន ៖ បាទ! ទប់ភ្លឺស្រែតូចៗ ហើយនឹងស្ទូងអីចឹង ហើយដល់ពេលខែហ្នឹងគេចាប់បញ្ជូនយើងទៅត្រពាំងថ្មវិញហើយ ។

ធានី ៖ ចឹងបានន័យថាឲ្យតែខែប្រាំង គឺពូត្រូវទៅប្រចាំការណ៍នៅត្រពាំងថ្ម?

សាវ៉ាន ៖ បាទ! ទៅត្រពាំងថ្មហ្នឹង ។

ធានី ៖ ប្រហែលប៉ុន្មានខែ មកនៅលើកទំនប់?

សាវ៉ាន ៖ ២ទៅ៣ខែរហូត ឥឡូវយើងចាប់ពីនេះទៅប្រហែល២ទៅ៣ ។

ធានី ៖ ចា៎! ត្រូវហើយ ៣ខែហ្នឹងយើងអាចទំនេរដៃ?

សាវ៉ាន ៖ អាចមកទំនេរដៃ ដល់ពេលខែវស្សាវិញ គេដកមួយចំនួនឲ្យមក ។

ធានី ៖ មកស្ទូង?

សាវ៉ាន ៖ ទៅស្ទូងដក បិទលើកទំនប់ល្អៗតូចៗ ។

ធានី ៖ ចឹងកាលពូនៅធ្វើកងចល័តហ្នឹង ហៅកងចល័តអីគេ?

សាវ៉ាន ៖ កងចល័តបើនិយាយរួមគេសំដៅអ្នកដែលមានវ័យពី១៥ អ្នកពេញវ័យ កងចល័ត ។ ខ្ញុំពាក្យថាកងចល័ត បានន័យថានិយាយថាកម្លាំងវាពិសេសម៉ងអាកងចល័តហ្នឹង គឺអាចមានការងារយើងទៅលើកណា ដកភ្លាមៗទៅ ។ បើកងមួយគេហៅកងតាវ៉ាល់ ។

ធានី ៖ ចា៎!កងតាវ៉ាល ។

សាវ៉ាន ៖ កងតាវ៉ាល់ហ្នឹងខ្លាំងណាស់ ។

ធានី ៖ កងពូមែន?

សាវ៉ាន ៖ មិនមែនទេ ពួកខ្ញុំអត់ដល់កងតាវ៉ាល់ៗនឹងសាហាវណាស់ ។

ធានី ៖ យ៉ាងម៉េច?

សាវ៉ាន ៖ យើងសាហាវយ៉ាងម៉េច យើងការលុតដុំរបស់គេខ្លាំងណាស់ ឧទាហរណ៍ថាយើងយឺតតែម៉ានាទីអីគេស្រាយអង្រឹងធ្លាក់ដាច់ងាប់ណា៎ ។

ធានី ៖ មានធ្លាក់ស្លាប់ទេ?

សាវ៉ាន ៖ មានៗកងតាវ៉ាល់ សាហាវណាស់ពួកហ្នឹង ។

ធានី ៖ ប៉ុន្មាននាក់ទៅ កងតាវ៉ាល់?

សាវ៉ាន ៖ កងតាវ៉ាល់ ខ្ញុំស្គាល់កងគេមិនបានទេ ព្រោះកងគេហៅកងពិសេស ។

ធានី ៖ កងពិសេស តែតាវ៉ាល់អ្នកគ្រប់គ្រង?

សាវ៉ាន ៖ គ្រប់គ្រងហ្នឹងគឺពូតែតាវ៉ាល់ៗ គេដឹងហើយ ។

ធានី ៖ តែកងពិសេសហ្នឹង អ្នកណាដែលអាចចូលកងពិសេសហ្នឹងបាន?

សាវ៉ាន ៖ និយាយរួម គេជ្រើសរើសតាមមូលដ្ឋាន អ្នកដែលមានកម្លាំងមាំមួនហើយណា៎ គឺថាអ្នកនោះអាចកម្លាំងទាំងយប់បាន មិនឈឺមិនថ្កាត់អីនេះអីចឹងណា គេយកទៅដាក់អ្នកដែលមានសុខភាព មាំមួន ហើយដូចពួកខ្ញុំ ។

ធានី ៖ មិនមែនអ្នកលុតដុំអីទេ?

សាវ៉ាន ៖ បាទ! កងតាវ៉ាល់ហ្នឹង គឺបានន័យថាអត់ត្រឡប់មកវិញទេ លើកនៅហ្នឹង ។

ធានី ៖ នៅទំនប់ត្រពាំងថ្មរហូត ខែវស្សាកលើកដែរ?

សាវ៉ាន ៖ បាទ! ជួនទៅនៅនោះលើករហូត តែបើដូចពួកខ្ញុំហ្នឹង ។

ធានី ៖ ត្រូវចល័តចុះចល័តឡើង?

សាវ៉ាន ៖ បាទ! ចល័តចុះចល័តឡើងអត់ទៀងទេ ។

ធានី ៖ កងតាវ៉ាល់ហ្នឹងមានគ្នាប៉ុន្មាននាក់ទៅ?

សាវ៉ាន ៖ ខ្ញុំមិនស្គាល់មិនបានទេ បើសុទ្ធតែកងរយដាងហើយ ។

ធានី ៖ រងរយដាង?

សាវ៉ាន ៖ រងរយ ទៅ៩០០ទៅ១០០០អីច្រើនណាស់ ឥឡូវនិយាយចឹងចុះ បើខ្ញុំឃើញវាច្រើនមែន វាកងពួកហ្នឹងពិសេស ឧទាហរណ៍ថាយប់ទៅយប់ បើពួកខ្ញុំជួនកាលលើកម៉ោង៦-៧ឈប់វិញ ហើយពួកអាហ្នឹង ។

ធានី ៖ ចឹងកងហ្នឹងលើកទាំងយប់ទាំងថ្ងៃ?

សាវ៉ាន ៖ បាទ! ទាំងយប់ទាំងថ្ងៃ តែកន្លែងណាសំខាន់ៗ គឺកងតាវ៉ាល់ហ្នឹងហើយ ។

ធានី ៖ កន្លែងសំខាន់កន្លែងម៉េច?

សាវ៉ាន ៖ កន្លែងថាមានទំនប់ដាច់យប់ វារឿងទំនប់កន្លែងណាវាត្រូវបាក់ ចង់បាក់ គឺយកកងទៅដាក់ហើយ ។

ធានី ៖ ទៅធ្វើភ្លាមៗ?

សាវ៉ាន ៖ បាទ! ទៅធ្វើភ្លាមៗ ព្រោះពួកហ្នឹងគេមានកម្លាំងមាំមួនណាស់ ហើយការហូបចុកគេៗគ្រាន់បើជាងពួកខ្ញុំ ។

ធានី ៖ គេទំនុកបំរុងការហូបចុកដែរ?

សាវ៉ាន ៖ បាទ! ម៉េចកងពិសេស គេឲ្យហូបគ្រប់គ្រាន់ជាងពួកខ្ញុំ ។ បើពួកខ្ញុំមានបាយដែរ តែការហូបចុកហ្នឹង វាម្ហូបអាហារអត់មានអីទេ មានទឹកកាបិ ទឹកប្រហុក ទឹកអី ។

ធានី ៖ មានបាយហូបដែរ?

សាវ៉ាន ៖ មានកាលហ្នឹង ឲ្យតែលើកចឹងគេឲ្យបាយហូប ។

ធានី ៖ ចឹងឲ្យតែលើកទំនប់ត្រពាំងថ្មសុទ្ធតែមានបាយហូបទាំងអស់?

សាវ៉ាន ៖ បាយឆ្អែត ប៉ុន្តែវាពាក់ព័ន្ធហ្នឹងការហូបវាគ្រប់គ្រាន់ ប៉ុន្តែជីវជាតិអត់មានទេ សំខាន់អនាម័យយើងអត់បានទៀត ។

ធានី ៖ រុយ មានរុយ?

សាវ៉ាន ៖ បាទ! រុយច្រើនណាស់ សន្ទូមនោះរុយច្រើនណាស់ ។

ធានី ៖ ម៉េចចឹងពូ កន្លែងហ្នឹងសំបូររុយម៉េច?

សាវ៉ាន ៖ ចុះបើជួនកាលគេរៀបលើកហ្នឹងដីអីចឹង ។

ធានី ៖ រៀបអីគេ បាយ?

សាវ៉ាន ៖ រៀបបាយហ្នឹងដីតាមវាលស្រែទៅ ចឹងបានថាអារុយក៏ពងដាក់រុយអី ។ ហើយទៅដល់បើសិនជាបបរវិញយើងចាប់បកមកចេញចង់អស់ហើយ ។ ចុះបើស៊ីម៉េចបើសុទ្ធតែពងរុយនៅហ្នឹងវាដាក់ពេលយើងធ្វើការ ។

ធានី ៖ បបរហ្នឹងគេជួស គេដាក់ចានៗរៀបឲ្យយើងយក?

សាវ៉ាន ៖ ហ្នឹងហើយអាបបរខាប់ៗ ជួនកាលបាយព្រឹកៗ ល្ងាចបបរ ប៉ុនចឹង ដល់ពេលចឹងយើងកាលជួសតាំងពីម៉ោង៩ម៉ោងអីគេទុកចោលដីហ៊ុយចោល អាខ្លះចឹងរុយរោមអីចឹង គ្មានអ្នកណាអង្គុយ ម៉ាការដ្ឋានៗមនុស្សរាប់រយរៀប ធ្វើម៉េចវាខ្វះអនាម័យ ។

ធានី ៖ ចឹងមិនមានអ្នកភាគរូសអីឈឺអី?

សាវ៉ាន ៖ មាន ។

ធានី ៖ ច្រើនទេ អាសន្នរោគអី?

សាវ៉ាន ៖ មានប៉ុន្តែវាមិនដែល មានព្រោះអាសន្នរោគមិនសូវជួប ប៉ុន្តែរៀងតិចតួច ប៉ុន្តែខ្ញុំជម្រាបថាទោះបីរាគរុះយ៉ាងម៉េចក៏ដោយក៏ខំប្រឹងប្រែងដែរ ឆាប់ធ្វើយើងវាមិនបានប្រឹងប្រែង គេថា

យើងឈឺសតិអារម្មណ៍ណា ។ ឈឺសតិអារម្មណ៍ ក៏យើងមិនបានរស់យូរដែរ ព្រោះបើតាមខ្ញុំដឹងស្លាប់ច្រើនណាស់ ។

ធានី ៖ ពូបានឃើញផ្ទាល់ភ្នែកទេ?

សារ៉ាន ៖ បាទ! ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ ប៉ុនឃើញគេចាប់យកដាក់ស្ពែន ហើយរហូតដល់គេចឹងគេថាអើយ!អាំ វែអាហ្នឹងមួយមិញស្រួលអីណា អាហ្នឹងស៊ីថ្នើមមនុស្ស ប៉ុនគេពាក្យគំរាមយើងក៏មិនដឹង ឬមួយគេធ្វើមែនក៏មិនដឹង ប៉ុន្តែភាគច្រើនមិនភ័ក្តរបស់ខ្ញុំដែលធ្វើការនៅការដ្ឋានហ្នឹង ខ្វះស្លាប់អស់ច្រើនណាស់ ស្លាប់ដោយសារបាក់កម្លាំង ដោយសារគេវៃចោល ។

ធានី ៖ វៃចោលនៅទំនប់ហ្នឹង កប់នៅហ្នឹងម៉េច?

សារ៉ាន ៖ កប់នៅហ្នឹង ចុះបើទំនប់ជើង១៥០ម៉ែត្រ កំពស់៥០ លើក៥០ណា ។ ប៉ុន្តែត្រពាំងថ្មនេះបើតាមខ្ញុំនេះដឹង គឺវាលើកអត់គ្រប់ដែនការគេទេ ។

ធានី ៖ ម៉េចចឹងពូ?

សារ៉ាន ៖ វាទឹកវាមកចឹង លើកពង្រួញវិញ ជើង៥០ ១៥០វាបាន៥០ ១០០ចឹង វាអត់បានគ្រប់ទេ ព្រោះទឹកវាច្រើនមក ។

ធានី ៖ ទឹកច្រើនមកពីណាវិញ?

សារ៉ាន ៖ ទឹកវាហូរមកពីភ្នំព្រះៗ ភ្នំវែងមកពីលើហ្នឹងហូរចាក់មក ។

ធានី ៖ មកពីកន្លែងហ្នឹងវាទាបជាងគេ?

សារ៉ាន ៖ បាទ! កន្លែងវាទាបជាងគេ ហើយតំបន់ហ្នឹង ។

ធានី ៖ គេជីកទាប?

សារ៉ាន ៖ បាទ! ដល់ចឹងតំបន់ហ្នឹងទឹកវាបុកទៅ វាធ្វើអត់គ្រប់ដែនការ ។

ធានី ៖ ចឹងអ្នកដែលធ្វើហ្នឹង ពេលខែវស្សា មិនទឹកច្រើនពិបាកធ្វើ?

សារ៉ាន ៖ ខែវស្សាហ្នឹងគេដកចេញហើយ ទុកតែមួយចំនួនណាទេ ដើម្បីថែរក្សាលើខ្នងទំនប់ ពេលវាច្រោះ វាងហូរពីលើដាក់តិចៗណា ។ បើសំខាន់កម្លាំងលើកធំគឺប្រាំង អាខែហ្នឹងចាប់ផ្តើមខែហ្នឹងគេដកទៅលើក តែដីស្ងួតគេចាប់ផ្តើម ។

ធានី ៖ ចឹងគេលើកៗម៉េចកើត មានទឹកមានអី?

សារ៉ាន ៖ ទឹកចេះ ដែលទឹកឯលើហើយ គេមានក្រោមខះនេះ ។

ធានី ៖ គេទប់ ចឹងអាខាងលើទឹកហូរមក យើងទប់លេង?

សារ៉ាន ៖ បាទ! យើងតក្លាប់ហើយ ដល់ចឹងយើងមានដីក្រោមស្លួត លើកខ្ពស់ណាស់ ហើយដាក់កម្រិត

ធានី ៖ ហើយដល់ពេលមនុស្សមានកប់នៅហ្នឹងដើងហ្នឹងច្រើនទៀត?

សារ៉ាន ៖ មានៗ គេវៃកប់ចោលហ្នឹងទំនប់ហ្នឹង ចុះមានអ្នកណាដឹង ហើយដល់ ។

ធានី ៖ មានច្រើន?

សារ៉ាន ៖ មានៗ ។

ធានី ៖ ភាគច្រើនមកពីណាវិញ អ្នកនៅដែលត្រូវគេសម្លាប់ហ្នឹង?

សារ៉ាន ៖ ភាគច្រើនចេះ ដែលខ្ញុំអាចដឹង អ្នកដែលមកពីភ្នំពេញ និយាយរួមគឺចិន ឬអ្នកដែលមិនបាន ឆ្លងកាត់អាការលំបាកពីមុនៗមក បើដូចជាខ្ញុំ ។

ធានី ៖ គេឲ្យលើកទំនប់ គេឲ្យមកលើកហ្នឹងដែរ តែលើកអត់រួចបានគេវៃចោល ឬមួយក៏គេយកពីអ្នក ផ្សេងមកវៃនៅហ្នឹង?

សារ៉ាន ៖ ចេះអ្នកអត់សកម្ម អ្នកឈឺច្រើន អ្នកតវ៉ា ។

ធានី ៖ ប៉ុន្តែសុទ្ធតែអ្នកនៅកងចល័តពូទេ?

សារ៉ាន ៖ អ្នកនៅហ្នឹង នៅជាមួយគ្នាហ្នឹង តវ៉ាច្រើន ហើយឈឺច្រើនចឹង ឥឡូវឯងករណីចុះ ប៉ុនពួក ហ្នឹងអត់ចូលចិត្តករណីហ្នឹង វាធ្វើតែត្រឹមទៅអ្នកណាតែខំប្រឹងប្រែងគឺដឹងថារស់ហើយ ដូចខ្ញុំរក បានដូចសព្វថ្ងៃនេះ ដោយសារខ្ញុំថាទោះបីខ្ញុំឈឺល្មមៗ ខ្ញុំទៅដែរ លើកលែងតែទៅមិនរួច ខ្ញុំ ប្រឹងហើយ តែអ្នកដែលទម្រន់គឺភាគច្រើនដឹងថាបាត់ខ្លួនម៉ង ព្រោះគេយកទៅម្តងមួយៗ ហើយជាពិសេសងាប់អាពេលយប់ ។ ឧទាហរណ៍ថាអ្នកងងឹតមាន់ មើលអត់ឃើញ គេធ្វើអា ដើងដីរីសម្រាប់បុកណា អាខ្លះហ្នឹងអ្នកដែលគ្នាកងធំៗ គេចង់ពិសោធន៍យើង ទៅឈរក្បែរ ទៅឈរក្បែរ ជួនកាលគ្នាងងឹតមែនៗ ហើយបុកដើងចំដើងគេ អាហ្នឹងគឺត្រូវតែងាប់ ហើយ ដូចមិត្តភ័ក្រ្តខ្ញុំ ។

ធានី ៖ ពូឃើញផ្ទាល់ភ្នែក?

សារ៉ាន ៖ បាទ! មិត្តភ័ក្រ្តខ្ញុំ ។

ធានី ៖ ឈ្មោះអីគេ?

សារ៉ាន ៖ ឈ្មោះអាហ៊ួ មិត្តភ័ក្រ្តខ្ញុំណា គ្នាងងឹតភ្នែកចេះតែលើកដីអត់កើតទេពេលយប់ ។

ធានី ៖ ប៉ុន្តែត្រូវទៅលើក?

សាវ៉ាន ៖ ដល់ចឹងគេពិសោធន៍ គេឲ្យបារីសេក គេឲ្យជក់ ហើយគេចង់ដឹងចឹង ទៅលូក ហើយមើលចុះ គ្មានអត់ដឹង ដល់ចឹងគេទៅឈរជិត បុកចំជើងគេ ចំជើងគេទៅ គេក៏អាចយកទៅសម្លាប់ចោល

ធានី ៖ យកទៅឃើញ?

សាវ៉ាន ៖ បាទៗ ដឹកថ្ងៃម៉ិង ប៉ុនអ្នកពេលម៉ោង១១ចឹង គេមកចាប់ពេលហូបបាយចឹង គេចាប់យកទៅ ខាងយកទៅវ៉ៃចោលណា ចូលព្រៃយើងមិនដឹងគេយកទៅវ៉ៃចោលណា យកទៅព្រៃអាហ្នឹង ពេលថ្ងៃ ។ បើពេលយប់គឺភាគច្រើនគេយកទៅវ៉ៃចោលទៅនោះ ។

ធានី ៖ ពូឃើញទេ?

សាវ៉ាន ៖ អឺ! ខ្ញុំកន្លងមក ខ្ញុំបានឃើញអ្នកដែលវ៉ៃផ្ទាល់នារីម្នាក់ណា ។

ធានី ៖ ចាំ! ឈ្មោះអីគេ?

សាវ៉ាន ៖ នារីនោះខ្ញុំ គាត់របៀបថាគាត់អត់ចេះនិយាយ គរ ប៉ុនខ្ញុំភ្លេចឈ្មោះគាត់ហើយ ។ អាហ្នឹងនៅ ការដ្ឋានជាមួយខ្ញុំដែរ ហើយគាត់ច្រើនតែហូបបាយអត់គ្រប់គ្រាន់ ហ្នឹងនារីក្រមុំដែរហ្នឹង ។ ហើយចេះបេះបោយអាស្រូវគេក្បែរៗអាស្រូវបាំងហ្នឹង ។ ហើយគេយកទៅវ៉ៃចោលហ្នឹង ខ្ញុំ ឃើញដាក់ស្ពែងហ្នឹង នារីហ្នឹងប្រហែលគេវ៉ៃ១៥០ប វ៉ៃ ។

ធានី ៖ ពូរាប់?

សាវ៉ាន ៖ វ៉ៃដាក់ក្បាលចងជាប់ហ្នឹងដើមត្រាចណ៎ា ហើយខ្ញុំគ្រាន់តែពេលថ្ងៃកំពុងសម្រាក ខ្ញុំសម្រាក ។

ធានី ៖ ពេលយប់ហ្នឹងពូ?

សាវ៉ាន ៖ ថ្ងៃ ។

ធានី ៖ ថ្ងៃទៀត?

សាវ៉ាន ៖ ភីផុសៗ ខ្ញុំគ្រាន់អើតមើល អ៊ុញពីណាវ៉ៃអី ដល់មើលទៅឃើញអាពួកឈ្លបគេវ៉ៃនារីហ្នឹង ហើយខ្ញុំក៏អត់ហ៊ាននៅយូរទេ ខ្ញុំរត់ចេញមក ។ ដល់ខ្ញុំរត់ចូលមកដល់កន្លែងខ្ញុំ ប្រាប់មិត្តភ័ក្រខ្ញុំ ថាមើល! នារីមួយដែលកហ្នឹង គេវ៉ៃចោលបាត់ហើយ នោះគេកប់មិនដឹងកប់ទេ ។ ដល់ចឹង ដល់ពេលហ្នឹង ក៏ខ្ញុំមកវិញ មកពេលដេកវិញ អាមួយដែលមកវ៉ៃហ្នឹង គេប្រាប់ខ្ញុំថា មិត្តឯង មិត្តសាវ៉ានឯងប្រឹងប្រែងណា ប្រយ័ត្នដូចនារីមួយខ្ញុំវ៉ៃចោលបាត់ហើយ ។

ធានី ៖ ប្រាប់ទៀត?

សាវ៉ាន ៖ បាទ! ប្រាប់ខ្ញុំ ហើយខ្ញុំ ប៉ុនខ្ញុំដឹងហើយណា ខ្ញុំញ័រចឹង ។

ធានី ៖   ឈ្មោះអីគេពូ ដែលប្រាប់ពូហ្នឹង?

សារ៉ាន ៖ គាត់ឈ្មោះ ញ៉ក់ ។

ធានី ៖   ញ៉ក់?

សារ៉ាន ៖ មាឌអត់ធំប៉ុន្មានទេ ។

ធានី ៖   គាត់ហ្នឹងធ្វើអីគេ?

សារ៉ាន ៖ ឈ្លប ។

ធានី ៖   ឈ្លបអីគេ?

សារ៉ាន ៖ ឈ្លបក្នុងការដ្ឋានៗគេមានដូចថា  គេមានដូចថាឈ្លបគេមួយ  សម្រាប់ស៊ើបអ្នកណា  ដែលសកម្ម មិនសកម្មចឹង អាហ្នឹងគេឈ្លបតាមដានទាំងយប់ គេដើរស្តាប់ចឹងណា ។

ធានី ៖   ចឹងពូ  ចុះពេលពូនៅកងចល័តហ្នឹង  គេហៅកងចល័តអី  ភូមិភាគ  តំបន់  ឬក៏សហករណ៍ហើយក៏ម៉េច?

សារ៉ាន ៖ អឺ! ព្រោះខ្ញុំកាលនោះចល័តដូចឃុំទេ ។

ធានី ៖   កងចល័តឃុំៗផ្អាំហ្នឹង?

សារ៉ាន ៖ បាទ!  ឃុំផ្អាំហ្នឹង  ព្រោះយើងប្រមូលគ្នាម៉ាឃុំទៅ  ដល់គេបូកចូលគ្នាទៅ  កាលនោះគេហៅតំបន់៥ ។

ធានី ៖   ចុះពូដឹងគណៈឃុំផ្អាំអ្នកណាគេ ហើយអ្នកណាធ្វើអីកងចល័ត?

សារ៉ាន ៖ អឺ!  តាអីនោះ  ខ្ញុំឈប់ចាំឈ្មោះគាត់បាន  វាយូរពេក  ប៉ុនគាត់ស្លាប់ហើយ  តាហ្នឹងដោយសារគាត់ធ្វើអំពើបាបពេក ហើយចុះក្រោយពួកខាងនិរតី ខាងតាកែវអីមក ។

ធានី ៖   មកសម្លាប់គាត់?

សារ៉ាន ៖ អត់ទាន់សម្លាប់ គាត់ចាក់ខ្លួនគាត់ ។

ធានី ៖   តាហ្នឹងឈ្មោះអីគេពូ ឃុំផ្អាំ?

សារ៉ាន ៖ អឺ! ខ្ញុំមិនដឹង ឃុំផ្អាំហ្នឹងខ្ញុំអត់ចាំឈ្មោះគាត់បាន ប៉ុន្តែគាត់គ្រប់គ្រងអាម៉ាឃុំហ្នឹង ហើយរហូតចុងក្រោយខាងនិរតីគេចុះមកហ្នឹង គាត់សម្លាប់ខ្លួនឯងដេកតាំងពីម៉ោង៧/ម៉ោង៨ គាត់ចាក់ខ្លួនគាត់ ។ ឃុំផ្អាំហ្នឹងខ្ញុំនិយាយរួម ខ្ញុំភ្លេចឈ្មោះគាត់ហើយ ព្រោះយើង៣០ឆ្នាំជាងហើយ បើសិនមុនខ្ញុំចាំ ប៉ុនឥឡូវខ្ញុំអត់ចាំទេ ។

ធានី ៖   គាត់ ឬក៏ តាហួត មិនមែនទេ តាហួត ពូស្គាល់តាហួត?

សារ៉ាន ៖ គាតហ្នឹងខ្ញុំ ។

ធានី :   នាម នឿមម៉េ ភូមិផ្គាំ?

សារ៉ាន : អត់ទេ បើសិនជាប្អូនឯងចាំមើលបានទៅខាងភូមិដើងវ៉ាន ។

ធានី :   ភូមិដើងវ៉ាន?

សារ៉ាន : អត់គេហៅភូមិយានវ៉ាងហ្នឹង សួរគេដឹងហើយ ។

ធានី :   យានវ៉ាង?

សារ៉ាន : បាទ! អ្នកដែលគ្រប់គ្រងអី! ។

ធានី :   នៅយានវ៉ាង?

សារ៉ាន : គ្រប់គ្រងកន្លែងការដ្ឋាននេះគឺឈ្មោះចឹងហើយ សួរគេប្រហែលជាគេដឹងហើយ អ្នកភូមិស្រុកកំណើតគេហ្នឹង ។

ធានី :   ខ្ញុំបានទៅដល់ដែរតើពូ?

សារ៉ាន : ចឹង ខ្ញុំវ៉ាអត់ចាំ ចឹងបើថ្ងៃណាទៅគោកកបិនសួរគេងអាចដឹងដែរ អ្នកដែលគ្រប់គ្រងកងចល័ត អ្នកដែលសម្លាប់ខ្លួនឯង ។

ធានី :   តាមឿន?

សារ៉ាន : ប្រហែលហ្នឹងដឹង ។

ធានី :   តាមឿន ប្រធាននៅខាងយានវ៉ាងផង នៅខាងផ្គាំផង?

សារ៉ាន : ប្រហែលហើយឈ្មោះហ្នឹងហើយ ។

ធានី :   ព្រោះពួកគាត់និយាយថា តាមឿនហ្នឹង ជាប្រធាន?

សារ៉ាន : អឺ! មានដល់ហ្នឹងដែរ មានចឹង ។

ធានី :   ចា៎! មានប្រធានសហករណ៍ ចង់សួរពូថាអាចប្រហែលឈ្មោះហ្នឹងអត់?

សារ៉ាន : អូ! ប្រហែលៗហ្នឹងហើយ ឥឡូវបានចាំថ្ងៃណាទៅដល់ទៀតសួរថា អ្នកដែលសម្លាប់ខ្លួននៅគេហៅអូររំចេកនៅភ្នំស្រុកណា៎ ដឹងហើយ ។ ប្រហែលជាមឿនហ្នឹងក៏មិនដឹង ។

ធានី :   ប្រុស ហើយស្រី ពូមានដឹងទេ?

សារ៉ាន : ដែលមេសម្លាប់ខ្លួនឯងហ្នឹងស្រី អឺ!ប្រុសទេ ។

ធានី :   ប្រុស ឈ្មោះមឿន អត់ច្បាស់ទេ?

សារ៉ាន : បើមឿននៅគោកកបិនអត់អីទេមឿនណាស់ ត្បិតតែមឿនគេថាមេឃុំមេអីនេះមេសហករណ៍ ហ្នឹងគឺគាត់ហ្នឹងហើយ មេសម្រាប់គ្រប់គ្រងកងចល័ត គឺគាត់ ។ ហើយគាត់ចុងក្រោយខាង និរតីមក គេគាត់សម្លាប់ខ្លួនឯងទេ ។

ធានី ៖ ចាំ! ខ្ញុំNoteទុកកន្លែងហ្នឹងមួយ គាត់សម្លាប់ខ្លួនឯង?

សារ៉ាន ៖ បាទ! នៅអូររំចេក ស្រុកភ្នំស្រុក ។

ធានី ៖ អាហ្នឹងគាត់ជាមេភូមិ មេក្រុមរបស់ពូ ឬក៏មេ?

សារ៉ាន ៖ មេៗគ្រប់គ្រងកងចល័តហ្នឹងហើយ គាត់អ្នកដឹកនាំ គាត់អ្នកគ្រប់គ្រងកងចល័តនេះ ប៉ុន្តែក្រោយមកខ្ញុំ គេដកខ្ញុំមកក្រោយវិញ ក៏គាត់ឮថាស្លាប់នៅហ្នឹងហើយ ស្លាប់នៅអូររំចេក ស្រុកភ្នំស្រុក ។

ធានី ៖ ចាំ! គាត់សម្លាប់ខ្លួនឯង?

សារ៉ាន ៖ បាទ! គាត់សម្លាប់ខ្លួនឯងដោយសារពួកនិរតី គេមកហ្នឹង ។

ធានី ៖ ចឹងពូនៅផ្តាំ បន្ទាប់មកទៀតបានពូចល័តចុះឡើងនៅត្រពាំងថ្មនៅអីចឹង?

សារ៉ាន ៖ បាទៗ ។

ធានី ៖ ចុះពូដែលស្គាល់ដឹងថាគណៈស្រុក អេ៎!ដឹងថាអ្នកណាគេគ្រប់គ្រងត្រពាំងថ្មហ្នឹងទេ បានការដ្ឋាន ហ្នឹង?

សារ៉ាន ៖ និយាយរួមចេះ អ្នកគ្រប់គ្រងត្រពាំងថ្មហ្នឹង គណៈតំបន់គេហៅតំបន់ណាំ ខ្ញុំមិនបានដឹងឈ្មោះគេទេ ព្រោះគេធំ ។

ធានី ៖ ស្រី ឬប្រុស គណៈតំបន់?

សារ៉ាន ៖ តំបន់ហ្នឹងប្រហែលជាប្រុសហើយ ។

ធានី ៖ តំបន់៥ ?

សារ៉ាន ៖ បាទ! តំបន់៥គឺ និយាយរួមតំបន់៥ ខ្ញុំធ្លាប់មេវាមិនបានព្រោះវា ។

ធានី ៖ ច្រើនពេក?

សារ៉ាន ៖ វាច្រើនពេក ព្រោះខ្ញុំគ្រប់គ្រងដឹងថាប៉ុន្មាននាក់ហ្នឹង អាកន្លែងខ្ញុំហ្នឹង ។

ធានី ៖ ឈ្មោះអីខ្លះដែលដឹងថាប៉ុន្មាននាក់នៅកន្លែងពូហ្នឹង?

សារ៉ាន ៖ និយាយរួមអ្នកដែលគ្រប់បន្ទាប់ពីតាដែលសម្លាប់ហ្នឹងមក ក៏មានស្អីមួយនេះ ខ្ញុំភ្លេចឈ្មោះ ត្រង់ហ្នឹងនិយាយរឿងហ្នឹងដែរ ប៉ុន្តែភ្លេចឈ្មោះ ។ ឈ្មោះស្អីទេ បងមួយនោះៗហើយគាត់ស្លាប់ដដែលហ្នឹង និយាយរួមខ្ញុំភ្លេចឈ្មោះគាត់ ។

ធានី ៖ ចឹងពូអត់ចាំឈ្មោះមេដឹកនាំរបស់ពូទេ?

សារ៉ាន ៖ ចាំ អត់ចាំឈ្មោះទេ ព្រោះវាយូរពេកហើយណា ។

ធានី ៖ យ៉ាងវ៉ាង...ចឹងនៅពេលដែលពូនៅតំបន់ ចឹងពូថាចឹងពូអត់ដែលដឹងថាភ្លេចឈ្មោះថាអ្នកដឹកនាំនៅហ្នឹងអ្នកណាខ្លះហើយ គ្រាន់តែដឹងការងារ ការលំបាកអីចឹង?

សាវ៉ាន ៖ ខ្ញុំគ្រាន់តែដឹងតែ និយាយរួមវាយូរពេក បើសិនវាៗដូចជា៣០ឆ្នាំជាងហើយ ដល់ចឹងភ្លេច ។

ធានី ៖ ចា៎! ភ្លេចអស់ហើយ ។

សាវ៉ាន ៖ សូម្បីតែមិត្តភ័ក្រ្តដែលធ្លាប់លើកដីជាមួយគ្នាក៏ភ្លេចឈ្មោះគ្នាដែរ ។

ធានី ៖ ដែលឃើញគាត់ទេ ឥឡូវមិត្តភ័ក្រ្តអស់ហ្នឹង?

សាវ៉ាន ៖ អាមិត្តភ័ក្រ្តនោះ តាមពិតឥឡូវជួបខ្លះ ដែលរស់ ប៉ុន្តែខ្លះមិនជួប ខ្លះគេរត់ឯលិចទៅ អាខ្លះក៏គេទៅភូមិស្រុកគេខាងឆ្ងាយៗ ខ្ញុំអត់ចាំ អត់បានជួប ។

ធានី ៖ ចឹងពេលពូនៅត្រពាំងថ្មហ្នឹង នៅពេលដល់វៀតណាមចូលមក ឬក៏យ៉ាងម៉េច?

សាវ៉ាន ៖ អត់ទេ ក្រោយមកអាខ្ញុំនៅត្រពាំងថ្ម អាចុងក្រោយហ្នឹង ខ្ញុំដូចខ្ញុំនិយាយចឹង ដោយសារខាងនិរតីគេចូលមក ដូច្នេះការគ្រប់គ្រងអាខាងផ្នែកពាយ័ព្យហ្នឹង វាខាងនិរតីគេចូលមកវាបែកបាក់ ខ្ចាត់ខ្ចាយទៅណា ហើយពេលហ្នឹងអាពេលយប់ហ្នឹងខ្ញុំពុកជំឡូងមី ពុលអីជងក៏នាំគ្នារត់មក មិនមែនរត់មកតែខ្ញុំមួយទេ គ្រប់កន្លែងទាំងអស់ គឺត្រូវតែរត់មកតាមភូមិវិញ ព្រោះខាងនិរតីគេចូលៗគ្រប់គ្រងទៅអាបាយអាអង្ករក៏អត់ស៊ី អាស្អីក៏អត់ស៊ីចឹងក៏នាំគ្នារត់ចូលមកតាម ខ្ញុំរត់ចូលទៅភូមិណា ទៅភូមិហ្នឹង ហើយ ។

ធានី ៖ ប៉ុន្មាននាក់ទៅ?

សាវ៉ាន ៖ ដែលរត់ហ្នឹងគឺ ច្រើនណាស់ និយាយរួមថាពាក្យថាច្រើនវា ដូចកន្លងមកភូមិនេះភូមិនោះ ដូចបាត់អាមេដឹកនាំចឹង ក៏នាំគ្នារត់មកៗតាមភូមិវិញ ហើយបើនៅកអត់អីស៊ីដែរ ។

ធានី ៖ ចុះការប្រធានក្រុនដឹកនាំលើកទំនប់ហ្នឹងឈ្មោះអីគេ ទំនប់ត្រពាំងថ្ម?

សាវ៉ាន ៖ ប្រធានដឹកនាំហ្នឹង ដូចខ្ញុំថាចឹង ថ្នាក់គេធំពេកនៅលើណា៎ ខ្ញុំមិនដឹងឈ្មោះពីណាពីណែទេ ។

ធានី ៖ អត់ចាំទេពូ ។ គ្រាន់តែដឹងថាតាអីដែលសម្លាប់ខ្លួនឯង?

សាវ៉ាន ៖ អាហ្នឹងតាខាងសហករណ៍ ដែលគាត់ក្តាប់ពួកខ្ញុំ គាត់សម្លាប់ខ្លួនគាត់ អាហ្នឹងហើយបានពួកខ្ញុំត្រូវរត់ ដែលគាត់ស្លាប់ទៅ ។

ធានី ៖ អូ! ចឹងដោយសារគាត់ស្លាប់ទៅ បានពូនាំគ្នារត់ទៅ?

សាវ៉ាន ៖ ហ្នឹងចឹងបានពួកខ្ញុំ ។

ធានី ៖ អត់ដឹងអ្នកក្រោយធ្វើអីទៀត?

សារ៉ាន ៖ បាទ! ដល់ចឹងបានគេ រត់ទាំងអស់ និយាយរួមរត់ទាំងអស់គ្រពាំងថ្ម ចាប់ពីថ្ងៃពេលហ្នឹងអា ពេលរត់ចេញមក គឺខ្ញុំរត់មកនៅភូមិគេ មកនៅការដ្ឋានតាម៉េងមួយទៀត អាការដ្ឋានដែលខ្ញុំថាលើកទំនប់ៗ ខ្ញុំមកនៅហ្នឹងលើកដីលើកទំនប់ដែរ ដល់ក្រោយមកហ្នឹង វៀតណាមវៃចូលមកនាំគ្នារត់បែកបាក់គ្នាទៀត ហើយក៏ខ្ញុំនាំម្តាយ និងប្អូនខ្ញុំមួយចំនួនហ្នឹង ខ្ញុំរត់មកនៅភូមិខ្ញុំវិញទៀត អឺ!នៅផ្ទះខ្ញុំវិញសព្វថ្ងៃហ្នឹងៗ

ធានី ៖ ចឹងចង់សួរពូកន្លែងពេលដែលពូនៅៗ ចឹងពេលដែលពូថាពូរត់មកផ្ទះហ្នឹង ចុះឪពុកពូពេលហ្នឹងគាត់គេចាប់ខ្លួនបាត់ហើយ?

សារ៉ាន ៖ ឪពុកខ្ញុំបេះ នៅឆ្នាំ៧៧ គាត់រត់ទៅថៃៗ

ធានី ៖ អូ! ឆ្នាំ១៩៧៧ គាត់រត់ទៅថៃ គាត់រត់រួចទេ?

សារ៉ាន ៖ អឺ! គាត់រត់រួច គាត់រត់ចោលខ្ញុំហើយណា ព្រោះគាត់ដូចថាការរស់នៅលំបាករបស់គាត់គឺវាលំបាកៗត្រង់ម៉េច ដោយសារគាត់មានឈ្មោះជាធ្វើកងទ័ពៗបម្រើលន់ នល់ គេបុករុកគាត់រហូតដល់គាត់ទ្រាំមិនបានអីចឹងៗ ហើយគាត់ក៏នាំគ្នារត់២០នាក់ ប៉ុន្តែស្លាប់អស់ៗ

ធានី ៖ ២០នាក់ហ្នឹងស្លាប់ទាំងអស់?

សារ៉ាន ៖ ២០នាក់ស្លាប់ទាំងអស់ រស់តែគាត់មួយទេៗ

ធានី ៖ អូ!

សារ៉ាន ៖ ហើយខ្ញុំក៏មិនដឹងថាគាត់រស់ទៀត ព្រោះពេលដែលពួកខ្ញុំរត់ទៅ គេបានគេចាប់បានអ្នករត់ទៅជាមួយខ្លះអីខ្លះមានស្រីមានប្រុសមក ហើយគេថាពុកខ្ញុំក៏ស្លាប់ដែរៗ

ធានី ៖ គេរត់មកវិញគេប្រាប់?

សារ៉ាន ៖ បាទៗ គេថាពួកគេថាពុកខ្ញុំក៏ស្លាប់ដែរ ចុះបើគេចាប់បានមកច្រើនៗ

ធានី ៖ ហ្នឹងហើយ!

សារ៉ាន ៖ ចឹងបានពុកខ្ញុំរត់ទៅដល់ថៃបានរហូតដល់៧៩ ខ្ញុំក៏អត់ដឹងថាគាត់រស់ផងពេលដែលខ្ញុំជិតចេញ មកពីតាម៉េង មកពីគោកកបិនហ្នឹង ខ្ញុំមកវិញៗ

ធានី ៖ មកផ្ទះ?

សារ៉ាន ៖ ហ្នឹងគេថាពុកឯងនៅឃើញហ្នឹងព្រៃនោះៗ ដល់ចឹងភ្ញាក់ណាស់ ដល់ឃើញគាត់ដើរមក គាត់ចេញរត់មកពីថៃវិញ គាត់មកពីថៃវិញៗ

ធានី ៖ ជួបពូនៅផ្ទះវិញ?

សារ៉ាន ៖ បាទ! ជួបនៅផ្ទះ ជួបព្រៃទៀត កាលហ្នឹងវៀតណាមមក គាត់អត់សូវហ៊ានមក ជួបៗ

ធានី ៖ ម៉េចចឹងពូ?

សារ៉ាន ៖ ចុះគាត់ខ្លាច ។

ធានី ៖ អូ! ខ្លាចដូចខ្មែរក្រហម?

សារ៉ាន ៖ បាទៗ ខ្លាចដូចខ្មែរក្រហម ចឹងបានគាត់ឲ្យបងប្អូនទៅយក មានអ្នកណាថាគាត់និយាយម្ដាយខ្ញុំ គាត់ថាហ៉ើ!គាត់ស្លាប់ហើយ គ្មានអ្នកណារស់ម្ដងទៀត ។ ដល់ពេលទៅបានដឹងថាគាត់រស់ មែន ចឹងបានថាមនុស្សយើងថា ។

ធានី ៖ អាយុថ្ងៃ?

សារ៉ាន ៖ អាយុថ្ងៃ ហើយពួកហ្នឹងនិយាយកុហកយើងម៉ង អាពួកខ្មែរក្រហមថា ពុកឯងស្លាប់ហើយ គ្មានអាណារស់នៅមួយស្លាប់ទាំងអស់ គេចាប់យកមកវ៉ៃចោលណាសម្លាប់ណាបាត់ហើយ ។ ហើយយើងដល់ពេលហ្នឹងលែងគិតថា គាត់ទៀតហើយ ពុក បានន័យថាគាត់ស្លាប់ហើយ ។

ធានី ៖ អាចដែរ បើសិនជាគាត់រត់មកស្រុកខ្មែរវិញគេចាប់សម្លាប់មែន?

សារ៉ាន ៖ ហ្នឹងហើយ ចេះគាត់រត់ទៅថៃ ។

ធានី ៖ រត់ផុត?

សារ៉ាន ៖ គាត់រត់ឆ្លងទៅថៃ ។

ធានី ៖ ចឹងដល់ពេលដែលពូរត់មកផ្ទះវិញនៅឆ្នាំ៧៩ កងទ័ពវៀតណាមចូលដល់ភូមិយើង ដល់កន្លែងពូនៅ?

សារ៉ាន ៖ អឺ!និយាយរួមកន្លែងការដ្ឋានហ្នឹងវៀតណាមអត់មានដល់ទេ ដោយសារឆ្លើលៗតៗគ្នាប៉ុនហ្នឹង ព្ទស្ទូរបាញ់គ្រាប់ចឹង បានន័យថាពួកខ្មែរក្រហមវាបាក់ហើយណា ។ ហើយក៏វារត់ យើងពេលហ្នឹងចឹងក៏យើងរត់ទៅ រត់តគ្នាចឹងរហូតនាំម៉ែឪចូលមក នាំមកផ្ទះវិញណ៎ ។ ចឹងមកដល់ហ្នឹងក៏មិនសុខដែរ មកដល់ហ្នឹងវាក៏នៅហ្នឹងខ្មែរក្រហមពួកអាពតនៅហ្នឹង ។

ធានី ៖ ចុះអាពេលកងទ័ពវៀតណាមចូលដល់ហើយ គឺពេលខ្មែរក្រហមរត់ចេញអស់ហើយម៉េច?

សារ៉ាន ៖ បាទៗ ។

ធានី ៖ ពេលហ្នឹងពូអត់រត់ទៅជាមួយគេទេ?

សារ៉ាន ៖ ពេលដែលខ្មែរក្រហមរត់មកការដ្ឋានដែលខ្ញុំថាមិញណ៎ ហើយខ្ញុំរត់មកផ្ទះខ្ញុំក៏មកដល់នេះក៏មានខ្មែរក្រហមទៀត ។ ហើយខ្មែរក្រហមនោះវានិយាយរួមវានៅក្បែរៗ ហើយវៀតណាមកាលនោះវាមានបានគ្រប់គ្រងទាំងស្រុងណា ។ ដូច្នេះរត់ចុះរត់ឡើង វៀតណាមចេញ ខ្មែរក្រហមចូលចឹង ។

ធានី ៖ ចឹងពូរត់ដែរ ឬក៏នៅតែភូមិហ្នឹងដដែល?

សារ៉ាន ៖ បាទ! រហូតយើងរត់ជម្លៀសចេញ ។

ធានី ៖ រត់ទៅណាវិញទៅ?

សារ៉ាន ៖ រត់ទៅនោះ ។

ធានី ៖ ទៅខាងណាភូមិ?

សារ៉ាន ៖ រត់ទៅលិច ។

ធានី ៖ ទៅភូមិឃុំអីគេកន្លែងហ្នឹង?

សារ៉ាន ៖ អារត់ហ្នឹងគេហៅអី! ត្រពាំងយាយនឹម ។

ធានី ៖ ត្រពាំងយាយនឹម?

សារ៉ាន ៖ បាទ!

ធានី ៖ នៅខាងណាវិញ?

សារ៉ាន ៖ នៅខាងត្បូង អឺ!ខាងត្បូងវល្លិ៍យាវ ខាងលិចវត្តខ្សាច់ល្អ ។

ធានី ៖ ហើយទៅខាងហ្នឹង ម៉េចក៏រត់ទៅម្តុំហ្នឹងចឹង?

សារ៉ាន ៖ កាលនោះបានន័យថា និយាយរួមដូចខ្មែរក្រហមគេកៀរយើងចឹង ព្រោះកុំឲ្យខ្លាចវាថាវៀតណាម មកសម្លាប់អីចឹង ។ អាហ្នឹងវាប្រទាញប្រទុងគ្នា ប្រទាញប្រទុងថាជណ្តើមប្រជាជនគ្នា អាពេលដែលរត់ទៅដល់ហ្នឹង ក៏វាសឹងតែសម្លាប់យើងដែរហ្នឹង ពួកខ្មែរក្រហមហ្នឹង ។

ធានី ៖ ចឹងពូរត់ទៅតាមខ្មែរក្រហម ឬតាមវៀតណាម?

សារ៉ាន ៖ កាលនោះរត់ទៅខ្មែរក្រហម ។

ធានី ៖ ម៉េចបានពូរត់ទៅជាមួយខ្មែរក្រហម ។

សារ៉ាន ៖ ចុះបើវាកៀរឲ្យចេញ ។

ធានី ៖ គេកៀរចេញ?

សារ៉ាន ៖ បាទ! កៀរចេញយកទៅនោះ ។

ធានី ៖ គេប្រាប់ថាម៉េច?

សារ៉ាន ៖ អាហ្នឹងវាមិនដឹងដែរ បើថានិយាយរួមកាលហ្នឹងវាចង់រើសក្មេងៗធ្វើទ័ពទៀត ប៉ុនដូចពួកខ្ញុំចេះ គេចពីណាពីណៃចាស់ៗទៅ ។

ធានី ៖ ហើយចឹងពូទៅដល់ហ្នឹង ហើយម៉េចបានត្រឡប់មកភូមិវិញ?

សារ៉ាន ៖ ដោយសារកាលនោះដូចថាវាមានកងទ័ពវៀតណាមមក យើងរត់មកវិញ ។

ធានី ៖ វៀតណាមគេកៀរយើងមកវិញ?

សាវ៉ាន ៖ អត់ទេ វៀតណាមកមកចឹង កាលនោះយើងទុកចិត្តវៀតណាមជាង ព្រោះវៀតណាមបាន រំដោះមកហើយ ។ ដូច្នេះ យើងឃើញវៀតណាមមកចឹង ក៏យើងមកវិញ ។

ធានី ៖ ពូឃើញក្នាមរត់មកវិញ?

សាវ៉ាន ៖ បាទ! នាំគ្នាមកវិញ ។

ធានី ៖ កងទ័ពខ្មែរក្រហម គេអត់ឃាត់ឃាំងយើង?

សាវ៉ាន ៖ ឃាំងអី បើវាខ្លាចវៀតណាមដែរអាពួកនោះគេច ដូចថាចឹង និយាយរួមទឹកដូចចចកចឹងណា ឡើងចុះចឹង ។

ធានី ៖ ហើយចឹងពូរត់មកវៀតណាមវិញ ម៉េចបានឆ្នាំ៨០បានពូចូលធ្វើទាហានជាមួយវៀតណាម?

សាវ៉ាន ៖ អឺ!ខ្ញុំមកនៅហ្នឹងអឺ!ខ្ទង់ឆ្នាំ៨០ហ្នឹង គេរើសចូលធ្វើទ័ពក៏ខ្ញុំ ។

ធានី ៖ ស្ម័គ្រចិត្តចូលហ្នឹងគេ?

សាវ៉ាន ៖ ស្ម័គ្រចិត្តទៅព្រោះកន្ទួងមកវាមានការឈឺចាប់ជាមួយរបបខ្មែរក្រហម ដោយសារវាធ្វើបាប ប្រជាជនក៏ដូចជារូបខ្ញុំចឹងណា៎ ។ ហើយកន្ទួងមកយើងមិនបម្រើ មិនការពារក៏វាចូលមកបាន ។

ធានី ៖ ចឹងពូការពារភូមិពូ?

សាវ៉ាន ៖ បាទ! មិនការពារទេ ដោយសារការពារមិនការពារពូមិនពូអីទេ ខាងណាក៏ការពារដែរ ព្រោះ ខ្ញុំពេលចូលបម្រើកងទ័ពហ្នឹងខ្ញុំបានទៅហ្វឹកហ្វឺននៅបាត់ដំបងនោះ ។ នៅបាត់ដំបងហើយរហូត មកខ្ញុំទៅដល់រហូតភ្នំពេញទៀត ។

ធានី ៖ ហ្វឹកហ្វឺនប៉ុន្មានខែ?

សាវ៉ាន ៖ ខ្ញុំចូលបាត់ដំបង៣ខែ រៀនមុនដំបូង គេថាចូលរៀនទាហានឲ្យដឹងច្បាប់ទម្លាប់ពីរបៀបរបបកង ទ័ពលូនក្រាបស្អីណា ។

ធានី ៖ ប៉ុន្មាននាក់ទៅដែលទៅជាមួយពូ?

សាវ៉ាន ៖ កាលខ្ញុំទៅរៀននោះប្រហែលជាស្មើនឹង៣០០ ។

ធានី ៖ អូ! ៣០០នាក់ សុទ្ធតែអ្នកភូមិយើង?

សាវ៉ាន ៖ អត់ទេ គេរើសម៉ាខេត្តបាត់ដំបង កាលនោះបន្ទាយមានជ័យយើង ។

ធានី ៖ គេហៅខេត្តបាត់ដំបង?

សាវ៉ាន ៖ មិនទាន់មានបន្ទាយមានជ័យទេ គេហៅខេត្តបាត់ដំបង ដូច្នេះរើសតាមស្រុកណា៎ ។

ធានី ៖ ហើយទៅរៀននៅភូមិភាគ ដូចថារៀននៅកន្លែងណាពូចាំទេ?

សារ៉ាន ៖ រៀននៅកន្លែងនេះ គេហៅនេះសាលាសកល ។ ស្គាល់សាកល?

ធានី ៖ អាកន្លែងហ្នឹងគេហៅស្អីគេ?

សារ៉ាន ៖ ឥឡូវគេដាក់វិទ្យាល័យស្អីគេទេ បែកចានដាប់បែកចាន ទល់មុខព្រលានយន្តហោះ ។

ធានី ៖ អូ! ទល់មុខសកលវិទ្យាល័យយើងរាល់ថ្ងៃហ្នឹង?

សារ៉ាន ៖ បាទៗ ទល់មុខហ្នឹង អាខាងកើតហ្នឹង អាសាលាគេរៀនរាល់ថ្ងៃ ។

ធានី ៖ កន្លែងហ្នឹងគេមានការដ្ឋានកីឡាគេមួយ?

សារ៉ាន ៖ បាទៗ ពីដើមគេដាក់ទ័ពទាំងអស់ អាសាលាដែលបង្រៀនហ្នឹងក៏ទ័ពដែរ ។

ធានី ៖ ហើយពូកាលហ្នឹងអ្នកណាគេអ្នកដឹកនាំពូ?

សារ៉ាន ៖ អឺ! កាលហ្នឹងបងឯកឧត្តមកុយ ប៊ុនថា គាត់ប្រធានយោធាខេត្ត ។

ធានី ៖ ឯកឧត្តមកុយ ប៊ុនថា?

សារ៉ាន ៖ បាទ! កុយ ប៊ុនថាហ្នឹង គាត់អ្នកគ្រប់គ្រងទាហានទាំងអស់ដែលទៅរៀនហ្នឹង ហើយគ្រប់គ្រងរួមម៉ាខេត្តហ្នឹងម៉ង់ហ្នឹង គេថាគាត់ជាមេបញ្ជាការយោធាខេត្ត កន្លងមកគេហៅមេបញ្ជាយោធាខេត្ត ។

ធានី ៖ មេបញ្ជាការ?

សារ៉ាន ៖ យោធាខេត្តបាត់ដំបង ។

ធានី ៖ យោធាខេត្ត?

សារ៉ាន ៖ បាទ!

ធានី ៖ ហើយពេលចឹងពូធ្វើការនៅហ្នឹងចឹងរហូត?

សារ៉ាន ៖ ខ្ញុំធ្វើចេះខ្ញុំធ្វើការបានដល់ឆ្នាំ៨៣ ពី៨០ដល់៨៣ណ៎ ។

ធានី ៖ ធ្វើជាទាហានធម្មតាហ្នឹង?

សារ៉ាន ៖ ធ្វើជាទាហានខាងវិទ្យុទាក់ទង ខាងវិទ្យុទាក់ទងរាល់ថ្ងៃគេហៅបញ្ជូនសារ ។

ធានី ៖ អូ! បញ្ជូនសារ រាល់ថ្ងៃគេហៅបញ្ជូន?

សារ៉ាន ៖ បាទ! គេហៅបញ្ជូនសារ ។

ធានី ៖ ពូខាងយោធាទាក់ទងទេ ៣ឆ្នាំ?

សារ៉ាន ៖ បាទៗ កន្លងតាំងពីអតីតរដ្ឋកម្ពុជាហ្នឹងគេហៅវិទ្យុទាក់ទង ។

ធានី ៖ ហើយដល់ពេលក្រោយមកទៀត ពូធ្វើអីទៀត?

សារ៉ាន ៖ អេ!ចេះ ចាប់ពី៨៣ខ្ញុំគេឲ្យទៅរៀននៅភ្នំពេញទៅរៀនគេហៅនៅសាលាឬស្សីកែវនៅភ្នំពេញ ផ្នែកគេហៅវគ្គមេបញ្ជាការវិទ្យុទាក់ទង ។

ធានី ៖ អូ! វគ្គមេបញ្ជាការវិញ?

សារ៉ាន ៖ បាទ! វគ្គមេបញ្ជាការវិទ្យុទាក់ទង ។

ធានី ៖ យ៉ាងម៉េចទៀតពូ ដល់ពេលក្រោយមកទៀត?

សារ៉ាន ៖ ហើយដល់ចឹងខ្ញុំរៀនចប់រយៈពេលម៉ាឆ្នាំ រៀនហ្នឹងឬស្សីកែវរយៈពេលម៉ាឆ្នាំ ។ ខ្ញុំបានគេដកគេបែងចែកទៅ ខ្ញុំក៏បានចូលទៅបម្រើការគេហៅស្នងការវិទ្យុទាក់ទងៗ នៅក្រសួងការពារជាតិ ។

ធានី ៖ ពូធ្វើស្នងការ ប្រធានស្នងការ?

សារ៉ាន ៖ អត់ទេៗ ខ្ញុំគ្រាន់តែនៅស្នងការវិទ្យុទាក់ទងនៅជាមួយគេ ចេញទៅគេជំនួយការទេ ចេញពីអាសាលាហ្នឹងមិញហ្នឹង ។

ធានី ៖ ចឹងពូជំនួយការគេទេ?

សារ៉ាន ៖ ជំនួយហ្នឹងជំនួយការៗមេ បានន័យថាជំនួយការមេនៅស្នងការវិទ្យុទាក់ទងណា៎ ។

ធានី ៖ ហើយរហូត?

សារ៉ាន ៖ រហូតមកដល់បច្ចុប្បន្ននេះ ខ្ញុំនៅតែធ្វើការងារហ្នឹង ។

ធានី ៖ នៅតែស្នងការ ឬក៏?

សារ៉ាន ៖ ផ្លូវគេ កាលពី៩០ រហូតដល់ពី ។

ធានី ៖ ពី៨៤មក?

សារ៉ាន ៖ ៨៤ដល់៩៣ បានពីស្នងការគេហៅបញ្ជាការដ្ឋាន បញ្ជូនសារ អគ្គបញ្ជាការ ។

ធានី ៖ បញ្ជូនសារ?

សារ៉ាន ៖ បាទ! បញ្ជាការដ្ឋាន ។

ធានី ៖ បញ្ជូនសារ?

សារ៉ាន ៖ បាទ! អគ្គសេនាធិការ ដាក់ទៅៗ ។

ធានី ៖ បញ្ជូនសារ អគ្គសេនាធិការ?

សារ៉ាន ៖ បាទៗ វាចំណុះអគ្គសេនាធិការហ្នឹងណា៎ ។

ធានី ៖ ចឹងពូមុខងារជាអី នៅក្នុងហ្នឹង?

សារ៉ាន ៖ អឺ! មិនខ្ញុំមេអីទេ ប៉ុន្តែខ្ញុំរាល់ថ្ងៃមកទល់ពីឆ្នាំ៩៣មកទល់បច្ចុប្បន្ននេះ ខ្ញុំអឺ!ឋានៈខ្ញុំវរសេនីយ៍ឯក ។

ធានី ៖ វរសេនីយ៍ឯក?

សារ៉ាន ៖ វរសេនីយ៍ឯក ។

ធានី ៖ សក្តិ៣ ចឹងពូ?

សារ៉ាន ៖ មិនសក្តិ៣ទេ ។

ធានី ៖ សក្តិប៉ុន្មាន?

សារ៉ាន ៖ សក្តិ៥ ។

ធានី ៖ អូ! ប្រឡំ ។ សក្តិ៥ ។

សារ៉ាន ៖ អនុសេនីយ៍ឯកបានសក្តិ៣ ហើយតួនាទីខ្ញុំរាល់ថ្ងៃហ្នឹងគឺ នាយការិយាល័យប្រតិបត្តិការណ៍សឹក បញ្ជាការដ្ឋាន ។

ធានី ៖ បញ្ជាការដ្ឋានបញ្ជូនសារ?

សារ៉ាន ៖ អគ្គបញ្ជាការ អានេះម៉ាគន្លាក់ ។

ធានី ៖ អានេះម៉ាគន្លាក់ អានេះម៉ាគន្លាក់ទៀត?

សារ៉ាន ៖ អានេះម៉ាគន្លាក់ទៀត ប្រហែលជាគេប្តូរឈ្មោះពីអគ្គសេនាធិការទៅជាអគ្គបញ្ជាការទៅ ។ ចឹង បងឯងដាក់អគ្គបញ្ជាការទៅ ។

ធានី ៖ ២សារចឹង?

សារ៉ាន ៖ ២សារ ពី៨៤មក៩៤នេះ ។

ធានី ៖ បញ្ជាការនេះ?

សារ៉ាន ៖ ខាងវិទ្យុ ។

ធានី ៖ នេះវិទ្យុទាក់ទងនេះ?

សារ៉ាន ៖ បាទ! អានេះបញ្ជាការដ្ឋានវិទ្យុទាក់ទងអគ្គសេនាធិការ ដល់ក្រោយមកគេកែប្រែទៅពី៩៣រហូតមកបច្ចុប្បន្ននេះ ទៅជាបញ្ជាការដ្ឋានបញ្ជូនសារអគ្គបញ្ជាការ ។

ធានី ៖ អគ្គសេនាធិការ ឬក៏អគ្គបញ្ជាការ?

សារ៉ាន ៖ អានេះអគ្គសេនាធិការ ដល់ក្រោយហ្នឹងអាក្រោយសរសេរមិញគឺអគ្គបញ្ជាការ ។

ធានី ៖ ចឹង ប៉ុន្តែពូមានតួនាទីជានាយការិយាល័យប្រតិបត្តការណ៍សឹករងអគ្គសេនាធិការ?

សាវ៉ាន ៖ មិនមែនទេ អាហ្នឹងធំណាស់ ឆាប់ ឥឡូវសរសេរណា សរសេរត្រង់នេះ ខ្ញុំប្រាប់ឡើងវិញ ឥឡូវ ។

ធានី ៖ ដល់ត្រឹម៩៣ដល់ឥឡូវ?

សាវ៉ាន ៖ ៩៣ដល់ឥឡូវ ខ្ញុំវរសេនីយ៍ឯក ដោក សាវ៉ាំ ហើយនៅ ។

ធានី ៖ ហើយនៅ?

សាវ៉ាន ៖ នាយការិយាល័យ ។

ធានី ៖ ពូនិយាយតាមសម្រួល ខ្ញុំកត់បានប៉ុន្មាន ខ្ញុំយកតាមហ្នឹង?

សាវ៉ាន ៖ នាយការិយាល័យប្រតិបត្តិការណ៍សឹក ។

ធានី ៖ អីទៀត នៅទៀត?

សាវ៉ាន ៖ អឺ! បញ្ជាការដ្ឋានបញ្ជូនសារ១ អគ្គបញ្ជាការ ចឹងណា៎ ។

ធានី ៖ អូ! ថែមអគ្គបញ្ជាការ?

សាវ៉ាន ៖ ហ្នឹងអគ្គបញ្ជាការ អានោះពីមុនវាអគ្គសេនាធិការ ឥឡូវយើងតាមរៀបតាមប្រព័ន្ធអាគេថា អាស៊ានហ្នឹង វាទៅជាអគ្គបញ្ជាការវាលែងមានអគ្គសេនាធិការហើយចឹង ។

ធានី ៖ ចឹងពូកាលពេល៨០ហ្នឹង ពូនៅក្រោមចំណុះអ្នកណាគេ កាលឆ្នាំ៨០ ៨៣ហ្នឹងនៅក្រោមចំណុះ?

សាវ៉ាន ៖ ៨០ ៨៣ហ្នឹង ខ្ញុំនៅចំណុះឯកឧត្តម កុយ ប៊ុនថា មិញហ្នឹងនៅយោធាខេត្ត ។

ធានី ៖ នៅបាត់ដំបង?

សាវ៉ាន ៖ បាទ! នៅយោធាខេត្តបាត់ដំបង ។

ធានី ៖ យោធាខេត្ត ហើយដល់ពេល៩៨?

សាវ៉ាន ៖ ៩៨ ខ្ញុំនៅស្នងការ ពី៨៣ដល់៨៨ខ្ញុំរៀននៅសាលាវិទ្យុទាក់ទង១ឫស្សីកែវ ។

ធានី ៖ សាលា១?

សាវ៉ាន ៖ សាលាឫស្សីកែវវិទ្យុទាក់ទង ។

ធានី ៖ សាលាឫស្សីកែវវិទ្យុទាក់ទងទៀតពូ ត្រឹមស្នងការនេះពូនៅចន្លោះហ្នឹង?

សាវ៉ាន ៖ ហើយរហូតពី៨៨រហូតដល់៩៣ហ្នឹង ខ្ញុំនៅស្នងការវិទ្យុទាក់ទង ។

ធានី ៖ នៅភ្នំពេញវិញ?

សាវ៉ាន ៖ នៅភ្នំពេញទាំងអស់អាហ្នឹង និយាយរួមនៅភ្នំពេញទាំងអស់ ។

ធានី ៖ និយាយតាំងពី៨៨ ដល់៩៣ រហូតដល់ឥឡូវពូនៅភ្នំពេញ?

សារ៉ាន ៖ បាទ! នៅភ្នំពេញទាំងអស់ ចឹងឥឡូវមកទល់បច្ចុប្បន្នក៏នៅភ្នំពេញដែរ ។

ធានី ៖ ចេះតាំងពីមុនរហូតមកដល់ តើពូយល់ថាការរស់នៅយ៉ាងម៉េចដែរ ចំពោះការរស់នៅដែលពូបានឆ្លងកាត់៤-៥របបហើយ?

សារ៉ាន ៖ ចេះខ្ញុំ ដែលខ្ញុំសង្កេបមកវិញ ដែលខ្ញុំរស់នៅក្នុងរបប ដែលខ្ញុំកើតទាន់ តាំងពីលន់ នល់ ខ្មែរក្រហមពួកកម្ពុជាប្រជាធិបតេយ្យ ហើយនឹងរដ្ឋកម្ពុជាមកទល់រាល់ថ្ងៃគេហៅព្រះរាជាណាចក្រកម្ពុជាហ្នឹង ការដែលខ្ញុំប្រៀបធៀបររស់នៅសព្វថ្ងៃ គេបានគ្រាន់បើជាងមុនឆ្ងាយណាស់ ព្រោះបានន័យថាខ្ញុំថាគ្រាន់បើ យើងគិតមើលឃើញថាទាំងជីវភាពប្រជាជន ក៏ដូចគ្រួសារខ្ញុំគឺបានធូរធារច្រើន កន្លងមកពីកាលសម័យមុនៗបើយើងនិយាយពីសាច់ការរៀនសូត្រក៏កូនសិស្សមិនបានរៀនសូត្រមិនបានទេ ។ ដូច្នេះបើប្រៀបធៀបប៉ុន្មានជំនាន់នេះមក បានន័យថាសង្គមហ្នឹងវាគ្រាន់បើជាងគេទាំងអស់ ខ្ញុំប្រៀបធៀបដូចនៅភ្នំពេញចឹងបើយើងគិតទៅពីដើម ពីសង្គមណាៗវាអត់មានស្ពានច្រើនទេ មានស្ពានតែ២មានស្ពានជ្រោយចង្វារ ហើយនឹងស្ពាន មុនីវង្សណា ។ តែឥឡូវយើងបានធ្វើស្ពានឆ្លងកាត់ព្រែកក្តាម ព្រែកព្នៅ ព្រែកតាម៉ាក់ ហើយនឹងស្ពានស្អីគេចេះ ។ ដូច្នេះបានន័យថាជីវភាពរស់នៅរាល់ថ្ងៃទោះបីថាវានៅក្នុងកម្រិតប្រជាជនកម្រិតទាប ប៉ុន្តែបើប្រៀបធៀប ជំនាន់នេះល្អជាង ប្រសើរជាង អាចថាប្រជាជនមានសិទ្ធិ ។ អីពីដើមដូចដឹងស្រាប់ហើយ ដូចខ្ញុំនិយាយពីរបបខ្មែរក្រហម មិនអាចនិយាយអីបានពេលណាពេលណៃទេ ។ ហើយរបបសព្វថ្ងៃនេះ យើងនិយាយមានសិទ្ធិបានទូលំទូលាយទោះបីនៅកន្លែងខ្លះមានចន្លៀតអីម៉េចក៏ដោយ ក៏យើងនៅតែថានៅគ្រាន់បើជាងគេ ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

សារ៉ាន ៖ ឪពុកខ្ញុំដោក នាម ។

ធានី ៖ គាត់នៅរស់ទេ រាលថ្ងៃ?

សារ៉ាន ៖ ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណា?

សារ៉ាន ៖ ឆ្នាំ៩០ ។

ធានី ៖ ៩០ ដោយសារអីគេ?

សារ៉ាន ៖ ដោយសារជម្ងឺ ។

ធានី ៖ ឈឺអីគេទៅ?

សារ៉ាន ៖ អាហ្នឹងដូចថាគាត់ឈឺសម្នាក់ដែលសម្នាក់ដើងជរាចាស់ ។

ធានី ៖ ហើយចុះម្ដាយ?

សារ៉ាន ៖ ម្ដាយ ឡុង ង៉ាម ។

ធានី ៖ ឡុង ង៉ាម ។ គាត់នៅរស់?

សារ៉ាន ៖ ស្លាប់ដូចគ្នា ប្រហែលជាឆ្នាំដូចគ្នាហ្នឹង តាមមើល ។

ធានី ៖ ហើយឈឺដូចគ្នាដែរ?

សារ៉ាន ៖ ព្រោះខ្ញុំកាលដែលគាត់មានបញ្ហាហ្នឹង គឺតំបន់ហ្នឹងនិយាយរួម ភាគីគេខាងព្រំដែនគេគ្រប់គ្រង បានខ្ញុំមកអត់បានទេ ។ ដូច្នេះរហូតដល់គាត់ឈឺស្លាប់ក៏ខ្ញុំអត់បាននៅមើលដែរ ។

ធានី ៖ ចឹងពូនៅប្រទុងប្រទះជាមួយនេះដែរ?

សារ៉ាន ៖ បាទ! ដូច្នេះតំបន់នេះពីឆ្នាំ៨៩ ខាងនេះខាងរណសិរ្សខាងអឺ!គាសឺន សាន រួមជាមួយកម្ពុជាប្រជាធិបតេយ្យ ហើយនឹងខាងសាមគ្គីគេហៅហ៊ុនស៊ីប៉ិចរាល់ថ្ងៃហ្នឹង គ្រប់គ្រងបាន ហើយខ្ញុំក៏មិនបានមកមើលគាត់ដែរ ។ ហើយគាត់ស្លាប់ឆ្នាំហ្នឹងទៅ ហើយខ្ញុំនៅតែភ្នំពេញទេ បើខ្ញុំមកៗបានត្រឹមស្វាយស៊ីសាផុន ខាងបន្ទាយមានជ័យ បានត្រឹកតែហ្នឹងទេ ។

ធានី ៖ ចុះបងប្អូនប៉ុន្មាននាក់ដែរ?

សារ៉ាន ៖ ខ្ញុំបងប្អូន៧នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សារ៉ាន ៖ អឺ! ស្រី៣ ប្រុស៤ ។

ធានី ៖ ស្លាប់ប៉ុន្មាន?

សារ៉ាន ៖ ប៉ុន្ដែរាល់ថ្ងៃស្លាប់ស្រីអស់២ ។

ធានី ៖ ដោយសារអីដែរ?

សារ៉ាន ៖ ដោយសារគាត់នៅភ្នំពេញ ទៅបម្រើពួកលន់ នល់ ធ្វើទាហានលន់ នល់ ហើយដល់ពេលគេរំដោះ៧៥ហ្នឹង គាត់ធ្វើដំណើរមកស្រុកវិញ ។ ដូចថាគាត់មានរបស់របរដូចជាមានម៉ូតូគេជិះជាប់ខ្លួនចឹង ក៏គេសុំ ព្រោះអានោះពាក្យថាស្នើថាមិនឲ្យវាដឹងថាង៉ាប់ហើយ ហើយគាត់បើមិនទុក គាត់ចង់ជិះម៉ូតូមកផ្ទះ ពូគេនិយាយ ថាគេសម្លាប់នៅកំពង់ឆ្នាំង ។

ធានី ៖ ឈ្មោះ២នាក់ហ្នឹង ឈ្មោះអីខ្លះដែលគាត់ស្លាប់ហ្នឹង?

សារ៉ាន ៖ ដឹង អឺនេះ ដោក ឈឹង ស្រី ។

ធានី ៖ ស្រី ហើយម៉េចទៀត?

សារ៉ាន ៖ ដោក គឹមសឿន ។

ធានី ៖ ដោក ឈីង?

សារ៉ាន ៖ បាទ! ដោក ឈីង ដោក គឹមសឿន ។

ធានី ៖ ២នាក់ហ្នឹងមកទាំង២?

សារ៉ាន ៖ បាទ! មកហ្នឹង មកជាមួយប្តីគាត់ ។

ធានី ៖ គាត់ហ្នឹងធ្វើជាទាហានលន់ នល់?

សារ៉ាន ៖ បាទ! ទាហានលន់ នល់ ។

ធានី ៖ ទាំង២នាក់?

សារ៉ាន ៖ គាត់ធ្វើនេះ អត់ទេ ប្រុស ប្តីបានធ្វើទាហាន ។

ធានី ៖ អូ! ទាំងគ្រួសារគាត់ទាំងពីរធ្វើទាហាន?

សារ៉ាន ៖ បាទៗ ។

ធានី ៖ ចុះគ្រួសារពូរៀបគ្រួសារឆ្នាំណា?

សារ៉ាន ៖ ឆ្នាំ ឈប់ខ្ញុំគិតមើល បើ៨០ប៉ុន្មានទេ ខ្ញុំការហ្នឹង ៨៤ ៨៥ទេ ។

ធានី ៖ ៨៤ ឬ៨៥?

សារ៉ាន ៖ តែឥឡូវដាក់៨៥ ។

ធានី ៖ ៨៥ កូនពូ កូនបងអាយុប៉ុន្មាន?

សារ៉ាន ៖ កូនខ្ញុំតែមួយមិញ ។

ធានី ៖ មួយស្រីហ្នឹង?

សារ៉ាន ៖ បាទ! ហ្នឹងហើយដាំបាយនៅទៀត ។

ធានី ៖ គ្រួសារពូឈ្មោះអី?

សារ៉ាន ៖ ជាប់សារិន ។

ធានី ៖ ជាប់ សារិន គាត់អ្នកស្រុកហ្នឹងដែរ?

សារ៉ាន ៖ នៅស្រុកកំណើតនឹងដូចគ្នាដែរ ។

វណ្ណៈ ៖ ចឹងពូទើបមានកូនក្រោយនេះ?

សារ៉ាន ៖ បាទៗ កន្លងមកវាបែកគ្នា និយាយរួមប្រពន្ធខ្ញុំនេះអត់បានសូវនៅជាមួយខ្ញុំប៉ុន្មានទេ ខ្ញុំទៅភ្នំពេញរហូតណា រាប់ឆ្នាំ ហើយអត់បានមកជួបគ្នាទេ ។

ធានី ៖ តាំងពី៨៤ទៅ?

សារ៉ាន ៖ បាទ! ៨៤ ។

វណ្ណៈ ៖ ពូការនៅនេះ?

សារ៉ាន ៖ ការនៅហ្នឹង ការរួច ខ្ញុំចូលទៅក្នុងរហូត ។

វណ្ណៈ៖ ចូលក្នុងលែងបាន?

សារ៉ាន ៖ បាទ!

ធានី ៖ បើសិនពូការនៅក្នុង ពូទៅឆ្នាំ៨៣ ទៅរៀននៅភ្នំពេញ ៨៤?

សារ៉ាន ៖ អត់ទេ អន្លាល់ខ្ញុំទៅរៀន៨៣ៗអត់ទាន់មានទេ ។

ធានី ៖ អាចផ្លាស់ចុះឡើង?

សារ៉ាន ៖ ដល់៨៥ហ្នឹងហើយ ខ្ញុំមកការ ។

ធានី ៖ ចុះពេលណាដែលខាងប៉ាវ៉ា ខាងអីគេគ្រប់គ្រងនៅខាងយើង?

សារ៉ាន ៖ ឆ្នាំ៨៩ៗ ។

ធានី ៖ ចឹង១៩៨៩ ប៉ាវ៉ាហ្នឹងគឺគ្រប់គ្រងនៅយើង?

សារ៉ាន ៖ តំបន់យើង ។

ធានី ៖ ប៉ុន្មានទៅ រហូតដល់ឆ្នាំប៉ុន្មានបាននេះ?

សារ៉ាន ៖ រហូតមក៩៣ដែលយើងចូលគ្នាហ្នឹង ។

ធានី ៖ កាល៩៣ហ្នឹងបាន ។

សារ៉ាន ៖ បាទៗ ។

ធានី ៖ ចឹងពូខ្ញុំអស់អីសួរពូ ពូមានចង់អីចង់និយាយ ឬក៏មានយោបល់អី?

សារ៉ាន ៖ ថាចេះបងនៅខាងណាដែរ ខ្ញុំភ្លេចបាត់ហើយ?

ធានី ៖ ខ្ញុំនៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកន្លែងហ្នឹងជាអង្គការក្រៅរដ្ឋាភិបាល ធ្វើការ ។

សារ៉ាន ៖ ឯកសារកម្ពុជា ចំណុះ គេដាក់ចឹងម៉ង?

ធានី ៖ ចាំ! ឈ្មោះវាចឹងម៉ង មជ្ឈមណ្ឌលឯកសារកម្ពុជា ។

សារ៉ាន ៖ មិននៅជាមួយឯកឧត្តម ស្អីលោកឆាំង យុហ្នឹងទេ ។

ធានី ៖ ហ្នឹងហើយ ពួកខ្ញុំនៅជាមួយលោកឆាំង យុ ។

វណ្ណៈ ៖ អង្គការបញ្ជាក់ថាអង្គការក្រៅរដ្ឋាភិបាល នៅអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សារ៉ាន ៖ បាទៗ ប្រាប់ថាឆាំង យុ ខ្ញុំដឹងហើយ ។

ធានី ៖ ពូធ្លាប់តាមដាន?

សារ៉ាន ៖ ហ៎! ខ្ញុំធ្លាប់មើលដែលលោកឆាំង យុ គាត់រៀបចំសុីណាឯកសាររហូតដល់កាត់ទោសខ្មែរក្រហមដោយសារគាត់ហ្នឹងហើយ ។

ធានី ៖ ពូបានតាមដានរឿងហ្នឹងដែរ?

សារ៉ាន ៖ តាមដានៗស្អិតណាស់នៅភ្នំពេញ ដោយសារខ្ញុំមកនេះខ្ញុំអត់មានពេលមើលទូរទស្សន៍មើលអី បើនៅនោះខ្ញុំមិនដែលខានទេ ។ ខ្ញុំមើលតាំងពីណាខ្ញុំចូលចិត្តមើលកម្មវិធីចឹងៗណា៎ ។

ធានី ៖ ពូចាប់អារម្មណ៍ ចុះពូដឹងរឿងតុលាការដែរ?

សារ៉ាន ៖ តុលាការខ្ញុំមិនបានចប់ចុងដើម ព្រោះអាហ្នឹងការងារច្រើនពេក ព្រោះអាហ្នឹងត្រូវការអង្គុយមើលយូរ ។

ធានី ៖ អត់ទេ ចង់សួរចិត្តពូដឹងមានតុលាការកាត់ទោសមេដឹកនាំខ្មែរ?

សារ៉ាន ៖ មានៗ ដឹងៗ ផ្ទះខ្ញុំនៅជិតហ្នឹងតើ ។

ធានី ៖ ហើយពូយល់ថាម៉េចដែរ ចំពោះរឿងហ្នឹង?

សារ៉ាន ៖ ខ្ញុំថាការកាត់ទោសខ្មែរក្រហមហ្នឹង ខ្ញុំយល់ថាវាគួរត្រូវតែកាត់ទោះបីរាល់ថ្ងៃហ្នឹងកាត់មិនបាន អស់ក៏ដោយ ប៉ុន្តែដើម្បីឲ្យអ្នកដែលស្លាប់ៗទៅវាបិទភ្នែកជិតព្រោះកន្លងមកវាអយុត្តិធម៌ ណាស់ ទាំងអ្នករស់ទាំងអ្នកស្លាប់សុទ្ធតែមានការលំបាកដោយសារពួករបបហ្នឹង កាត់ប៉ុន្មាន គ្រឿងនេះទៅអស់អានេះបានន័យថាវាអស់ចិត្តហើយណា ។

ធានី ៖ ចឹងមានអីចង់ថែមទៀតទេ?

សារ៉ាន ៖ ខ្ញុំអត់មានអីថែមទៀតទេ ទាល់តែខាងហ្នឹងសួរបានខ្ញុំឆ្លើយ បើថាឲ្យមានយោបល់អីផ្សេងៗខ្ញុំដូចជាមិនមានអីទៀតទេ ។

ធានី ៖ ចឹងអរគុណពូច្រើន ។

សារ៉ាន ៖ បាទៗ ។

«ចប់»